00726394

នៅចំពោះមុខអង្គបុរេជំនុំជម្រះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

D11/4/1

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ០៥)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 08 / 09 / 2011
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ សាធារណៈ:កោសលុប Chanrath

ប្រភេទចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted]

---

**ដាក់ដោយ៖**

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គីមសួន

លោកស្រី Silke STUDZINSKY

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គីមសាន ប្រធាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម CHUNG Chang-ho

ចៅក្រម Rowan DOWNING

**<u>សហចៅក្រមស៊ើបអង្កេត</u>**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Siegfried BLUNK

**<u>សហព្រះរាជអាជ្ញា៖</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានប្រកាសថា កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ត្រូវបានបំពេញចប់សព្វគ្រប់ហើយ[១] ។

២. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ [redacted] (ម្ចាស់បណ្តឹងឧទ្ធរណ៍) បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ នៅអង្គភាពគាំពារជនរងគ្រោះ។ ទម្រង់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិដែលមានលោកមេធាវីជាតិ ហុង គឹមសួន និងលោកស្រីមេធាវីអន្តរជាតិ Silke STUDZINSKY ជាអ្នកតំណាងផ្នែកច្បាប់របស់[redacted][២]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី [redacted] មានលេខរៀង 11-VSS-00003 ជាលេខសម្គាល់នៃការចុះបញ្ជីនៅអង្គភាពគាំពារជនរងគ្រោះ[៣]។

៣. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំចូលមើលសំណុំរឿង ០០៣[៤] ហើយនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្ញើសារអេឡិចត្រូនិកមួយដោយមានភ្ជាប់នូវទម្រង់ចាំបាច់មួយចំនួន[៥]។ លោក លី ច័ន្ទតុលា ក្រឡាបញ្ជី បានឆ្លើយតបមកវិញថា ពាក្យសុំនេះមិនទាន់ត្រូវបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតនៅឡើយទេ។ ទោះបីជាមេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍បានព្យាយាមសរសេរសារអេឡិចត្រូនិកដើម្បីសាកសួរជាច្រើនដង *បន្ទាប់ពីបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីអង្គភាព*

---

[១] សូមមើល http://www.eccc.gov.kh/en/articles/statement-co-investigating-judges។

[២] លេខឯកសារឯកសារពាក់ព័ន្ធមិនអាចដាក់បានឡើយ ដោយសារមិនអាចចូលមើលសំណុំរឿងបាន។

[៣] នៅក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី (ពាក្យសុំដែលមានលេខសម្គាល់ D22/0017 សម្រាប់សំណុំរឿង០០១ និងពាក្យសុំលេខ D25/16 សម្រាប់សំណុំរឿង០០២) និងបានចូលរួមផ្តល់សក្ខីកម្ម នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៩ និងថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៩ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំង ឌុច (លេខ ERN 00368453-00368462 និងលេខ ERN 00370760-00370786 )។

[៤] លេខឯកសារឯកសារពាក់ព័ន្ធមិនអាចដាក់បានឡើយ ដោយសារមិនអាចចូលមើលសំណុំរឿងបាន។

[៥] សារអេឡិចត្រូនិករបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី Silke Studzinsky និង ហុង គឹមសួន ផ្ញើទៅក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតដែលមានចំណងជើងថា "សំណើសុំមើលសំណុំរឿង ០០៣" ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១, ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១, ថ្ងៃទី ៦ ខែ មិថុនា ឆ្នា ២០១១ និងថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១។

*គាំពារជនរងគ្រោះទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១* ក៏ដោយ ក៏មេធាវីមិនបានទទួលការឆ្លើយតបអ្វីផ្សេងទៀតឡើយ។

៤. នៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១១ មានតែម្ចាស់បណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះដែលបានទទួលការជូនដំណឹងអំពី "ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈ្មោះ [redacted]" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ (**ដីកាសម្រេច**)[៦]។ មេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានទទួលការជូនដំណឹងអំពីដីកានេះឡើយ បើទោះបីជាខ្លួនបានស្នើសុំយ៉ាងច្បាស់លាស់ឱ្យផ្តល់ការជូនដំណឹងអំពីដីកាសម្រេចដែលគ្រោងនឹងចេញនោះក៏ដោយ[៧]។

៥. ដូចនេះ [redacted]ដែលមានតំណាងផ្នែកច្បាប់ សូមប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់[redacted]។

## II. ច្បាប់ និងវិធានជាធរមាន

៦. ច្បាប់ និងវិធានផ្ទៃក្នុងពាក់ព័ន្ធដែលបណ្តឹងឧទ្ធរណ៍នេះយោង មាន៖ វិធាន ១៤, ២១, ២៣, ២៣*ស្ទួន*, ២៣*ស្ទួនបួន*, ៥៣, ៥៥ និង ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៧), មាត្រា ១០ ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**ច្បាប់ អ.វ.ត.ក**)[៨], មាត្រា ៥(២) និង ៥(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (**កិច្ចព្រមព្រៀង**)[៩], *សេចក្តីប្រកាសអំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារ*

---

[៦] ក.ស.ច.ស "ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted]" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១, សំណុំរឿង០០៣, ឯកសារលេខD11/3។

[៧] មើលសារអេឡិចត្រូនិក, ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១។

[៨] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦)។

[៩] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

*ឧក្រិដ្ឋកម្ម និងការបំពានអំណាច* (**គោលការណ៍មូលដ្ឋាន**)[១០], *គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានរួមលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ* (**គោលការណ៍មូលដ្ឋាន និងការណែនាំ**)[១១], *គោលការណ៍របស់អង្គការសហប្រជាជាតិប្រឆាំងនឹងនិទណ្ឌភាព*[១២], មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[១៣] និងមាត្រា ៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ (**សេចក្តីណែនាំអនុវត្ត**)[១៤]។

## III. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍

៧. វិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុងគឺជាវិធានពិសេសសម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

---

[១០] *សេចក្តីប្រកាសអំពីគោលការណ៍ជាសារវ័ន្តនៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច* ដែលបានអនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៤០/៣៤ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ("ពីពេលនេះទៅហៅថា "គោលការណ៍ជាសារវ័ន្តអំពីភាពយុត្តិធម៌សម្រាប់ជនរងគ្រោះ")។

[១១] *គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានរួមលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ,* សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៦០/៣៤ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ("ពីពេលនេះទៅហៅថា "គោលការណ៍មូលដ្ឋាន និងការណែនាំ"), អាចមើលបាននៅ៖ http://www2.ohchr.org/english/law/remedy.htm។

[១២] និទណ្ឌភាព, របាយការណ៍របស់ជំនាញការងារឯករាជ្យដើម្បីផ្តល់ព័ត៌មានថ្មីៗអំពីគោលការណ៍នានាប្រឆាំងនឹងនិទណ្ឌភាព, Diane Orentlicher, ឯកសារបន្ថែម៖ គោលការណ៍ថ្មីៗសម្រាប់ការការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រឆាំងនឹងនិទណ្ឌភាព, ឯកសាររបស់អង្គការសហប្រជាជាតិ លេខ E/CN.4/2005/102/Add.1 ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៥, អាចមើលនៅ៖ http://daccess-dds-ny.un.org/doc/UNDOC/GEN/G05/109/00/PDF/G0510900.pdf?OpenElement។

[១៣] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២២០០ក (XXI), ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ហើយចូលជាធរមាន នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦, អាចមើលនៅ ៖ http://www2.ohchr.org/english/law/ccpr.htm។

[១៤] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ, អាចមើលនៅ ៖ http://www.eccc.gov.kh/en/documents/legal/practice-direction-victims-participation-revision-1។

នានារបស់ ក.ស.ច.ស លើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[១៥]។ បញ្ញត្តិពិសេសសម្រាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការទទួលយកពាក្យសុំ កំណត់យ៉ាងច្បាស់លាស់អំពីបទដ្ឋាននៃបណ្ដឹងឧទ្ធរណ៍។ សំអាងហេតុត្រូវបានកំហិតត្រឹមកំហុសឆ្គងលើអង្គហេតុ និង/ឬ លើអង្គច្បាប់ ក្នុងការចេញសេចក្ដីសម្រេច។

## IV. ការទទួលយកបណ្ដឹងឧទ្ធរណ៍

៨. យោងតាមវិធាន ៧៧*ស្ទួន*(១) និង (២)នៃវិធានផ្ទៃក្នុង ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល ១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីដីកាសម្រេចនោះ។ ដោយហេតុថា ម្ចាស់បណ្ដឹងឧទ្ធរណ៍បានទទួលដំណឹងអំពីដីកាសម្រេចលើការទទួលយកក្នុងសំណុំរឿង ០០៣ នៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១១ កាលបរិច្ឆេទសម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាសម្រេចនេះ គឺថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១។

៩. អនុលោមតាមវិធាន ៧៥នៃវិធានផ្ទៃក្នុង សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍នេះត្រូវបានដាក់ទៅអង្គបុរេជំនុំជម្រះ (អ.ប.ជ) នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១[១៦]។

១០. ដីកាសម្រេចរងការជំទាស់របស់សហចៅក្រមស៊ើបអង្កេតនេះមានសេចក្ដីសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ដូចនេះ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះអាចទទួលយកបានទាំងអង្គហេតុ និងទាំងពេលវេលា។

## V. កំណត់សម្គាល់បឋម

១១. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា វាជាការព្រួយបារម្ភយ៉ាងខ្លាំងនៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានយកចិត្តទុកដាក់ដល់តំណាងផ្នែកច្បាប់របស់ [redacted] បណ្ដឹងឧទ្ធរណ៍ ដោយមិនត្រឹមតែមិនទទួលស្គាល់តំណាងទាំងនេះ និងបដិសេធមិនឱ្យ

---

[១៥] វិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុងត្រូវបានអនុម័តដំបូងនៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១០ និងនៅមានសុពលភាពក្នុងវិសោធនកម្មទី៧ នៃវិធានផ្ទៃក្នុង។ វិធាននេះបានចូលជាធរមាននៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។

[១៦] រហូតដល់ពេលសរសេរបណ្ដឹងឧទ្ធរណ៍នេះ វាមិនពុំទាន់មានលេខសម្គាល់នៅឡើយ។ ឯកសារនេះមិនអាចដាក់លេខសម្គាល់បានឡើយដោយសារមិនអាចចូលមើលសំណុំរឿងបាន។

តំណាងចូលមើលសំណុំរឿងទេ តែថែមទាំងថា ស.ច.ស បានធ្វើការជូនដំណឹងតែម្ចាស់បណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះអំពីការបដិសេធលើលើពាក្យសុំរបស់គាត់។ ជាងនេះទៀត ស.ច.ស បានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ *ដោយខ្លួនដឹង* ថា [redacted] បណ្តឹងឧទ្ធរណ៍មិនរស់នៅរាជធានីភ្នំពេញ, *ដឹងថា* [redacted] មានការលំបាកជាក់ស្តែងក្នុងការទាក់ទងជាមួយមេធាវីរបស់ [redacted] និង *ដឹងថា* [redacted] បណ្តឹងឧទ្ធរណ៍ក្នុងស្ថានភាពបច្ចុប្បន្ននឹងត្រូវចំណាយពេលវេលា និងថវិកាបន្ថែមដើម្បីបញ្ជូនសំណៅដីកាសម្រេចនេះទៅតំណាងផ្នែកច្បាប់ក្នុងរាជធានីភ្នំពេញ នៅពេលគ្មានប្រព័ន្ធអ៊ីនធឺណិត និងគ្មានចំណេះដឹងក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនោះ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកថា នេះគឺជាសកម្មភាពគិតទុកជាមុនរបស់សហចៅក្រមស៊ើបអង្កេត ដែលធ្វើឡើងដោយចេតនា (ឬយ៉ាងហោចណាស់ដោយការធ្វេសប្រហែស) ដើម្បីកាត់បន្ថយរយៈពេលកំណត់ចំនួន ១០ថ្ងៃសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ យោងតាមនីតិវិធីជាបន្ទាន់ដែលមានចែងក្នុងវិធាន ៧៧*ស្ទួន*នៃវិធានផ្ទៃក្នុង។ ការធ្វើដូចនេះរំលោភលក្ខខណ្ឌតម្រូវនៃការគោរពសិទ្ធិរបស់ជនរងគ្រោះដែលផ្ទុយទៅនឹងវិធាន ២១(១) និង ២១(១)(គ)នៃវិធានផ្ទៃក្នុង។

១២. យើងអាចពិចារណាទៅលើករណីនេះដោយពិនិត្យលើសេចក្តីសម្រេចរបស់ ស.ច.ស ក្នុងការ "ផ្តល់" ពេលវេលាបន្ថែមសម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីសប្តាហ៍ដែលបានធ្វើឡើងកាលពីថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១, ដោយសេចក្តីសម្រេចនោះត្រូវបានប្រកាសតែមួយថ្ងៃមុន "កាលបរិច្ឆេទកំណត់ដែលបានបន្ថែម" ដែលតាមពិតបានផុតកំណត់រួចទៅហើយមកដល់ពេលនោះ[១៧]។ ដូចនេះ ការពន្យារពេលវេលាកំណត់សម្រាប់ករណីសេចក្តីសម្រេចនោះតាមពិតមានរយៈពេលតែមួយថ្ងៃ, ត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័ររបស់តុលាការដែលជាការគ្មានន័យអ្វីឡើយសម្រាប់ម្ចាស់ពាក្យសុំដែលមានចំនួនជាង ៩០% រស់នៅក្នុងខេត្ត និងតាមតំបន់នានានោះ។

១៣. ការបារម្ភយ៉ាងខ្លាំងមួយផ្សេងទៀតគឺថា តាមរយៈការមិនឆ្លើយតបនេះ ស.ច.ស បន្តមិនទទួល

---

[១៧] សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសំណើសំណុំរឿង០០៣ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១, ជារួម មើលរបាយការណ៍របស់អង្គការ យុត្តិធម៌សង្គមសេរីសម្រាប់យុត្តិធម៌អន្តរជាតិ, ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១, អាចមើលនៅ ៖ http://www.soros.org/initiatives/justice/articles_publications/publications/cambodia-eccc-20110614។

ស្គាល់តំណាងផ្នែកច្បាប់ក្នុងសំណុំរឿង០០៣ និងសំណុំរឿង ០០៤ ហើយអាស្រ័យហេតុនេះហើយ ទើបបដិសេធមិនឲ្យតំណាងផ្នែកច្បាប់ទាំងនេះចូលមើលសំណុំរឿង។

១៤. ការធ្វើដូចនេះមានន័យថា សហចៅក្រមស៊ើបអង្កេតបដិសេធជនរងគ្រោះមិនឲ្យចូលរួមឲ្យបានសមរម្យក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ និងប្រើប្រាស់សិទ្ធិរបស់ខ្លួន ដែលផ្ទុយទៅនឹងបញ្ញត្តិស្តីពីភាពយុត្តិធម៌ អនុលោមតាមវិធាន ២១នៃវិធានផ្ទៃក្នុង។

## VI. ឧឡឹករណ៍

### ១. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍

***ស.ច.ស បានរំលោភវិធាន ២១(ក)នៃវិធានផ្ទៃក្នុងដែលចែងពី "ដើម្បីធានាសច្ចភាពគតិយុត្តិ និងតម្លាភាព" នៅពេលបដិសេធមិនទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ដោយសំអាងថា [redacted] មិនមែនជា "ជនរងគ្រោះផ្ទាល់"***

១៥. ដីកាសម្រេចរងការជំទាស់នេះរំលោភគោលការណ៍ជាមូលដ្ឋានស្តីពីភាពយុត្តិធម៌ ដូចជា សច្ចភាពគតិយុត្តិ និងតម្លាភាព ពីព្រោះគោលការណ៍ទាំងនេះមានបញ្ជាក់ក្នុងវិធាន ២១(ក)នៃវិធានផ្ទៃក្នុង។ នេះហាក់ដូចជាបង្ហាញថា មូលដ្ឋានសម្រាប់បដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺថា [redacted] មិនមែនជាជនរងគ្រោះ "ផ្ទាល់" ហើយមូលហេតុនេះធ្វើឲ្យអ្នកដាក់ពាក្យសុំមិនអាចទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ យោងតាមដីកានេះ បុគ្គលម្នាក់ជាជនរងគ្រោះ "ផ្ទាល់" លុះត្រាតែបុគ្គលនោះមានទំនាក់ទំនងផ្ទាល់ជាមួយព្យសនកម្មរបស់ខ្លួន និងមានបង្ហាញបទល្មើស[១៨]។ ដីកានេះបញ្ជាក់ថា គ្មានទំនាក់ទំនងព្យសនកម្ម (ព្យសនកម្មផ្លូវចិត្ត)ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលរងឡើយ ពីព្រោះការងារដោយបង្ខំដែលស្វាមីរបស់ [redacted] បានទទួលរងគឺជា "ទំនាក់ទំនងអន្តរការី"[១៩]។ តាមរយៈការសម្រេចបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងដោយផ្អែកលើ "មូលហេតុទាំងនេះ" ស.ច.ស បានងាកចេញពីគោលនយោបាយរបស់ខ្លួនក្នុងរយៈពេល ៥ឆ្នាំកន្លងទៅនេះដោយគ្មានការកែប្រែលើមូលដ្ឋានច្បាប់សម្រាប់លក្ខខណ្ឌតម្រូវទទួលយកពាក្យសុំតាំងខ្លួន

---

[១៨] មើលដីកាសម្រេច, កថាខណ្ឌ ៥-៧ (សេចក្តីសន្និដ្ឋានដកស្រង់ចេញពីវិធាន ២៣ស្ទួន(១)(ខ)នៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត) ។

[១៩] មើលដីកាសម្រេច, កថាខណ្ឌ ៥។

ជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ជាងនេះទៀត ស.ច.ស បានសម្រេចបដិសេធដោយគ្មានផ្តល់ព័ត៌មានអ្វីមួយដល់ជនរងគ្រោះ ឬផ្តល់មូលហេតុលម្អិតថាតើហេតុអ្វីបានជាខ្លួនប្រកាន់យកវិធីតឹងរ៉ឹងដូចនេះក្នុងសំណុំរឿង ០០៣ (និងសំណុំរឿង ០០៤)។ វិធីសាស្ត្រថ្មីនេះប្រាសចាកពីបទដ្ឋានអន្តរជាតិ និងយុត្តាធិការច្បាប់ស៊ីវិលផ្សេងៗទៀត ទាក់ទងនឹងសិទ្ធិរបស់ជនរងគ្រោះ។

១៦. ប្រសិនបើមូលដ្ឋានមិនត្រឹមត្រូវនៃការបដិសេធនេះត្រូវបានយកទៅអនុវត្តនៅក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ វិញ ប្រហែលជាអ្នកដាក់ពាក្យសុំចំនួន ៨៦ ក្នុងចំណោម ៩០ ត្រូវបានគេច្រានចោលមិនខាន ដោយសារថាមានតែអ្នកដាក់ពាក្យសុំចំនួន *បួន* នាក់ប៉ុណ្ណោះ ដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកជាអ្នករស់រានមានជីវិតដោយផ្ទាល់ ("ជនរងគ្រោះផ្ទាល់")[២០]។ នៅក្នុងសំណុំរឿង ០០២, ការអនុវត្តដូចនេះអាចនាំដល់ការកាត់បន្ថយចំនួនដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់យ៉ាងច្រើនដែលទោះបីយ៉ាងណាក៏ដោយ ក៏ ស.ច.ស បានទទួលស្គាល់ពួកគេរួចទៅហើយ។

១៧. ជាងនេះទៀត ការអនុវត្តវិធីនេះជាការមិនសមហេតុផលឡើយ ប្រសិនបើអនុវត្តក្នុងស្ថានភាពដែលជនរងគ្រោះផ្ទាល់បានទទួលមរណភាព ពីព្រោះវិធីនេះមិនអនុញ្ញាតឱ្យសមាជិកគ្រួសារម្នាក់អាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីបានទេ។ ការបដិសេធរបស់ ស.ច.ស ផ្អែកលើមូលដ្ឋាននេះ បានបង្ហាញយ៉ាងច្បាស់ថា មិនមានការអនុវត្តនូវវិធាន និងគោលការណ៍ឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ទេ តែមាន ការពាក់ព័ន្ធនឹងការគិតគូរពិចារណា និងទទួលឥទ្ធិពលនយោបាយ។

## សេចក្តីសម្រេចរបស់ ស.ច.ស លើអង្គហេតុ និងអង្គច្បាប់

១៨. ស.ច.ស យល់ឃើញថា "អ្នកដាក់ពាក្យសុំមិនបានធ្វើការបង្ហាញថា ព្យសនកម្មរូបរាងកាយ [បន្ថែមការបញ្ជាក់]គឺជាផលវិបាក**ដោយផ្ទាល់**នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់"[២១]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា នេះគឺជាអះអាងមិនត្រឹមត្រូវ ពីព្រោះម្ចាស់ពាក្យសុំ

---

[២០] រហូតដល់ពេលសរសេរបណ្តឹងឧទ្ធរណ៍នេះ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងកំពុងស្ថិតនៅក្រោមបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[២១] ក.ស.ច.ស "ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted]" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ D11/3, កថាខណ្ឌ ៥។

អះអាងថា គាត់គ្មានព្យសនកម្មរូបរាងកាយទេ ប៉ុន្តែបញ្ជាក់ថា គាត់រងព្យសនកម្មផ្លូវចិត្ត។ ច្បាស់ណាស់ ដីកាសម្រេចនេះធ្វើឡើងដោយខ្វះការយកចិត្តទុកដាក់ចាំបាច់ក្នុងការពិនិត្យអំណះអំណាងលើអង្គហេតុរបស់ម្ចាស់ពាក្យសុំ។

១៩. ស.ច.ស បញ្ជាក់ថែមទៀតថា ពាក្យថា "ផ្ទាល់" នៅក្នុងបរិបទនេះមានន័យថា "ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់បានបង្កជាផលវិបាកដោយផ្ទាល់ ដោយពុំមានទំនាក់ទំនងហេតុ និងបច្ច័យជាអន្តរការីណាមួយឡើយ" ហើយថា "ទំនាក់ទំនងអន្តរការីដែលបង្កឱ្យមានព្យសនកម្មផ្លូវចិត្ត ដែលអ្នកដាក់ពាក្យបានលើកឡើងគឺជាការងារដោយបង្ខំដែលប្រព្រឹត្តទៅលើ [redacted] [របស់ [redacted] ពាក្យសុំ]"[២២]។ នៅក្នុងដីការបស់ខ្លួន ស.ច.ស បន្តលើកឡើងថា "ដោយហេតុថា ច្បាប់នៃទំនាក់ទំនងហេតុ និងបច្ច័យគឺជាច្បាប់បែបធម្មជាតិនិយម ច្បាប់នេះមិនមែនទុកចន្លោះណាមួយសម្រាប់ការបកស្រាយ ឬឆន្ទានុសិទ្ធិនៅក្នុងការអនុវត្តឡើយ។ ហេតុដែលនាំឱ្យកើតមានបច្ច័យ គឺអាចបណ្តាលឱ្យកើតមានបច្ច័យនោះដោយផ្ទាល់ ឬដោយអន្តរការី"[២៣]។

២០. ក្រៅពីនេះ ស.ច.ស ព្យាយាមគាំទ្រទឡ្ហីករណ៍របស់ខ្លួនដោយធ្វើការច្រានចោលឯកសារយោងពាក់ព័ន្ធយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ថា ការិយាល័យរបស់ខ្លួនបានចេញដីកាសម្រេចមួយចំនួនលើការទទួលយកពាក្យសុំ ក្នុងសំណុំរឿង ០០២ ពីខែ សីហា ដល់ខែ កញ្ញា ឆ្នាំ ២០១០។ ស.ច.ស បញ្ជាក់ថា ការយោងទៅយុត្តិសាស្ត្ររបស់ ICC មិនពាក់ព័ន្ធឡើយ ពីព្រោះនិយមន័យនៃ "ជនរងគ្រោះ"ក្នុងវិធាន ៨៥(ក)នៃវិធានស្តីពីភស្តុតាង និងនីតិវិធី (RPE) របស់តុលាការ ICC បានរាប់បញ្ចូលយ៉ាងច្បាស់លាស់នូវជនទាំងឡាយណាដែលជាសមាជិកគ្រួសារនៃជនរងគ្រោះផ្ទាល់។ ព្យសនកម្មប្រយោលអាចធ្វើឱ្យបុគ្គលម្នាក់ជាជនរងគ្រោះបាន ហើយដូចនេះ យើងមិនអាចយោងទៅតុលាការ ICC ក្នុងករណីនេះឡើយ។

២១. ការពិនិត្យលើនិយមន័យនៃពាក្យ "ជនរងគ្រោះ" បង្ហាញថា ការអះអាងរបស់ ស.ច.ស មានការភ័ន្តច្រឡំ។

២២. វិធាន ៨៥(ក)នៃវិធានស្តីពីភស្តុតាង និងនីតិវិធី (RPE) របស់ តុលាការ ICC កំណត់និយមន័យនៃជនរងគ្រោះថា ៖

[២២] ដីកាសម្រេច, កថាខណ្ឌ៥។

[២៣] ដីកាសម្រេច, កថាខណ្ឌ៥។

*"រូបវន្តបុគ្គលដែលបានទទួលរងព្យសនកម្មដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ"។*

២៣. អ.វ.ត.ក ប្រើប្រាស់**និយមន័យដូចគ្នា**នៃជនរងគ្រោះ ថាជា

*"រូបវន្តបុគ្គល [...] ដែលបានទទួលរងព្យសនកម្មដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក"*[២៤]

២៤. និយមន័យដូចគ្នាដូចមានលើកឡើងខាងលើបង្ហាញពីភាពពាក់ព័ន្ធជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការ ICC ក្នុងការបកស្រាយនិយមន័យនៃ "ជនរងគ្រោះ" របស់ អ.វ.ត.ក។ អង្គហេតុដែលថា និយមន័យរបស់តុលាការ ICC អំពីជនរងគ្រោះ រាប់បញ្ចូលយ៉ាងច្បាស់ទាំងសមាជិកគ្រួសាររបស់ជនរងគ្រោះ ហាក់ដូចជាជម្រុញឱ្យមានការបកស្រាយបែបនេះអំពី "ជនរងគ្រោះ" នៅ អ.វ.ត.ក ដោយបញ្ចូលសាច់ញាតិរបស់ជនរងគ្រោះផ្ទាល់។ ដូច្នេះ វាមានភាពពាក់ព័ន្ធយ៉ាងច្បាស់លាស់ និងសមស្របក្នុងការយោងទៅនិយមន័យនៃជនរងគ្រោះនៅតុលាការ ICC ដើម្បីគាំទ្រដល់ ការបង្កើតពាក្យនេះនៅ អ.វ.ត.ក។

២៥. ជាងនេះទៀត នៅក្នុងដីការងការជំទាស់ ស.ច.ស ច្រានចោលដោយភ័ន្តច្រឡំចំពោះការយោងទៅតុលាការ ICC ហើយការិយាល័យ ស.ច.ស ខ្លួនឯងបានទទួលយកការយោងនេះនៅក្នុងដីកាសម្រេចមុនៗទាំងអស់លើការទទួលយកពាក្យសុំ។ វិធីដែលបានប្រើក្នុងដីកាសម្រេចមុនៗគឺថា ដើម្បីទទួលស្គាល់ពាក្យសុំ ព្យសនកម្មដែលអ្នកដាក់ពាក្យបានទទួលរងមិនចាំបាច់ជាព្យសនកម្មផ្ទាល់នោះទេ ប៉ុន្តែវាត្រូវតែព្យសនកម្មជាលក្ខណៈបុគ្គល។ ដូចគ្នានេះដែរ ស.ច.ស បានសម្រេចក្នុងដីកាមុនៗលើការទទួលយកពាក្យសុំក្នុងឆ្នាំ ២០១០ ថាមានការសន្មតពីព្យសនកម្មផ្លូវចិត្តដែលសមាជិកសាច់ញាតិជិតស្និទ្ធរបស់របស់ជនរងគ្រោះផ្ទាល់ដូចជា ឪពុកម្តាយ, សហព័ទ្ធ និងបងប្អូនបង្កើត មាន។ ស.ច.ស បានសម្រេចថា ការសន្មតនេះនឹងត្រូវចាត់ទុកថាត្រឹមត្រូវ ក្នុងករណីជនរងគ្រោះផ្ទាល់បាត់ខ្លួន, ស្លាប់ ឬត្រូវបានជម្លៀសចេញពីគ្រួសារជិតស្និទ្ធដោយបង្ខំដែលជាផលវិបាកផ្ទាល់នៃអង្គហេតុស្ថិតក្រោមកិច្ចស៊ើបសួរ[២៥]។

---

[២៤] សន្ធានុក្រមវិធានផ្ទៃក្នុង។

[២៥] មើលឧទាហរណ៍ ៖ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅ ខេត្តបន្ទាយមានជ័យ, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D416, កថាខណ្ឌ ១៣-១៤។

២៦. តាមរយៈការសម្រេចបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ស.ច.ស បានរំលោភបំពានលើគោលការណ៍អំពីភាពយុត្តិធម៌ និងជាពិសេសគោលការណ៍នៃតម្លាភាព និងសច្ចភាពគតិយុត្តិ ដូចមានចែងក្នុងវិធាន ២១នៃវិធានផ្ទៃក្នុង។ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២[២៦] *ដោយផ្អែកលើអង្គហេតុដូចគ្នាបេះបិទនឹងអង្គហេតុ*[redacted]បានលើកឡើងក្នុងពាក្យសុំក្នុងសំណុំរឿង ០០៣ ពោលគឺព្យសនកម្មផ្លូវចិត្តបណ្តាលមកពីផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនានាស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ និងបានប្រព្រឹត្តប្រឆាំងនឹងស្វាមីរបស់[redacted]។

២៧. ស.ច.ស ទទួលស្គាល់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០២ ដូចខាងក្រោម ៖

> *"ទោះបីជាចៅក្រមស៊ើបអង្កេតបានទទួលយកអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ នៅក្នុងករណី "ព្រលានយន្តហោះកំពង់ឆ្នាំង/ព្យសនកម្មផ្លូវចិត្ត"ក៏ដោយ ក៏វាមិនទាន់មានភាពច្បាស់លាស់ទេថា នៅក្នុងសេចក្តីសម្រេចនេះ លក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធផ្ទាល់នៃទំនាក់ទំនងហេតុ និងបច្ច័យ ត្រូវបានពិនិត្យស៊ីជម្រៅនៅពេលចេញសេចក្តីសម្រេចនៅពេលនោះ ...។ ទោះស្ថិតក្នុងកាលៈទេសៈបែបណាក៏ដោយ ទឡ្ហីករណ៍នានាដែលមានក្នុងសេចក្តីសម្រេច និងត្រូវបានធ្វើឡើងក្នុងសំណុំរឿងខុសគ្នានេះ មិនមែនលក្ខណៈចាប់បង្ខំតម្រូវឱ្យគោរពនោះទេ ហើយក៏មិនអាចជាឧបសគ្គដល់សហចៅក្រមស៊ើបអង្កេត (បច្ចុប្បន្ន) ក្នុងការអនុវត្តបទប្បញ្ញត្តិនៃវិធាន ២៣ស្ទួន(១)(ខ) ក្នុងលក្ខណៈត្រឹមត្រូវនោះឡើយ"*[២៧] ។

២៨. ស.ច.ស បានទទួលស្គាល់បន្ថែមទៀតម្ចាស់បណ្តឹងឧទ្ធរណ៍ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ៖

> *"ទោះបីជានៅក្នុងសាលក្រមសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ការណ៍នេះគ្រាន់តែពាក់ព័ន្ធនឹងការសម្លាប់*[redacted]*នៅស២១ តែប៉ុណ្ណោះ ហើយវាមិនមានជាប់ពាក់ព័ន្ធជាមួយនឹងការងារ*

---

[២៦] សំណុំរឿងលេខ ០០២-១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅ ខេត្តព្រៃវែង, ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខD410, កថាខណ្ឌ ១៣-១៤។

[២៧] ដីកាដែលរងការជំទាស់, ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ៧។

*ដោយបង្ខំ ដែលប្រព្រឹត្តលើ[redacted]ដូចបានលើកឡើងនៅក្នុងពាក្យសុំនេះនោះទេ”*[២៨] ។

២៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ព្រលានយន្តហោះកំពង់ឆ្នាំង មិនស្ថិតនៅក្រោមវិសាលភាពនៃកិច្ចស៊ើបសួរ ហើយក៏មិនត្រូវបានពិនិត្យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ឡើយ។ ដូចនេះ វាគ្មានអ្វីដែលគួរឱ្យចម្លែកទេដែលថា ម្ចាស់បណ្តឹងមិនត្រូវបានទទួលស្គាល់ដោយសារតែឧក្រិដ្ឋកម្មនេះ។ អង្គហេតុនេះមិនបានរារាំង លោកស្រី ឬមិនធ្វើឱ្យពាក្យសុំរបស់លោកស្រីមានចំណុចខ្សោយនាំដល់ការមិនទទួលយក[redacted]ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ទាក់ទងនឹងព្រលានយន្តហោះកំពង់ឆ្នាំងឡើយ។

៣០. ទោះបីជា ស.ច.ស មានការភ័ន្តច្រឡំលើអង្គច្បាប់មួយចំនួនក្នុងដីការងការជំទាស់ក៏ដោយ ក៏ការភ័ន្តច្រឡំជាក់ស្តែងនោះគឺភាពមិនស៊ីសង្វាក់គ្នាលើការបកស្រាយអង្គច្បាប់លើវិធាន និងសេចក្តីណែនាំអនុវត្ត ដែលជាការរំលោភបំពានយ៉ាងច្បាស់លើវិធាន ២១(១)នៃវិធានផ្ទៃក្នុង ដែលជាវិធានធានានូវតម្លាភាព និងសច្ចភាពគតិយុត្តិក្នុងកិច្ចដំណើរការនីតិវិធី។

៣១. ដូចគ្នានេះដែរ ចៅក្រម **យូ ប៊ុនឡេង** ជាចៅក្រមស៊ើបអង្កេតដដែលដែលបានចេញដីកាសម្រេចស្តីពីការទទួលយកពាក្យសុំក្នុងសំណុំរឿង០០២។ នៅក្នុងករណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ចៅក្រមរូបនេះខកខានមិនបានអនុវត្តឱ្យបានស៊ីសង្វាក់គ្នានូវការបកស្រាយសេចក្តីណែនាំអនុវត្ត និងវិធានផ្ទៃក្នុងដែលគាត់បានធ្វើការបកស្រាយក្នុងករណីពីមុនៗទេ។ ទោះបីជាយ៉ាងនេះក៏ដោយ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការបញ្ជាក់ថា សច្ចភាពគតិយុត្តិ និងភាពស៊ីសង្វាក់គ្នា មិនពាក់ព័ន្ធនឹងចៅក្រមណាមួយឡើយ ប៉ុន្តែវាទាក់ទិននឹងការិយាល័យសហចៅក្រមស៊ើបអង្កេតដែលជាអង្គភាពតុលាការរបស់ អ.វ.ត.ក។ អាស្រ័យហេតុនេះ ការឈប់ពីការងាររបស់ចៅក្រមអន្តរជាតិ **ម៉ារសែល ឡឺម៉ុង** (Marcel Lemonde) និងការចូលជំនួសកន្លែងរបស់គាត់ដោយចៅក្រមអន្តរជាតិថ្មី មិនបង្កឱ្យមានការប្រែប្រួលចេញពីគោលការណ៍ដើមរបស់ការិយាល័យនេះឡើយ ជាពិសេស ប្រសិនបើគោលនយោបាយ ឬវិធីសាស្ត្រថ្មី មិនបានទទួលការគាំទ្រពីកម្រិតអន្តរជាតិ ឬពីកម្រិតជាតិ និងខ្វះមូលដ្ឋានច្បាប់។

---

[២៨] ដូចខាងលើ, កថាខណ្ឌ៨។ ដោយសារព្រលានយន្តហោះកំពង់ឆ្នាំង មិនស្ថិតនៅក្រោមវិសាលភាពនៃកិច្ចស៊ើបសួរ ហើយក៏មិនត្រូវបានពិនិត្យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ នោះ វាគ្មានអ្វីដែលគួរឱ្យចម្លែកទេដែលថាម្ចាស់បណ្តឹងមិនត្រូវបានទទួលស្គាល់ដោយសារតែឧក្រិដ្ឋកម្មនេះ។

៣២. គោលការណ៍សច្ចភាពគតិយុត្តិតាមន័យចង្អៀត *(sensu stricto)* មានន័យថា មនុស្សគ្រប់រូបមានសិទ្ធិរំពឹងថាទទួលបានលទ្ធផលមួយតាមផ្លូវតុលាការដែលអាចព្យាករណ៍បាន និងបានការការពារពីការសម្រេចដែលមិនត្រឹមត្រូវ។ ការបដិសេធចោលដោយគ្មានយុត្តិកម្មចំពោះអ្នកដាក់ពាក្យសុំនៅក្នុងដីកាដែលរងការជំទាស់នេះ រំលោភលើគោលការណ៍យុត្តិធម៌ តម្លាភាព ការទទួលខុសត្រូវ និងសច្ចភាពនៃវិធាន២១។ ទង្វើនេះក៏បានរំលោភផងដែរទៅលើគោលការណ៍នីតិរដ្ឋ ដែលថាប្រសិនបើអនុវត្តឱ្យបានស៊ីសង្វាក់គ្នា ចំពោះអង្គហេតុ*ដដែល* និងអង្គច្បាប់*ដដែល* នោះនឹងនាំឱ្យមាន*លទ្ធផលដដែល*មិនខាន[២៩]។

៣៣. ការអះអាងរបស់ ស.ច.ស ដែលថា ការទទួលស្គាល់ម្ចាស់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ "ក្នុងករណីផ្សេងៗទៀត គ្មានលក្ខណៈចាប់បង្ខំតម្រូវឱ្យគោរពតាមនោះទេ" គឺជាការអះអាងដោយភ័ន្តច្រឡំ។

៣៤. អង្គហេតុដែលថា សំណុំរឿងនេះមានលក្ខណៈខុសគ្នា ឬថា ជនត្រូវចោទផ្សេងៗមានការពាក់ព័ន្ធនឹងកន្លែងឧក្រិដ្ឋកម្មដែលបានស៊ើបអង្កេតក្នុងសំណុំរឿងមុន មិនបង្កឱ្យមានផលប៉ះពាល់ដល់បុរេលក្ខខណ្ឌដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ផ្ទុយទៅវិញ អង្គហេតុទាំងនេះត្រូវតែទទួលបានការពិចារណាស្មើៗគ្នា ពីព្រោះអង្គហេតុដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានបង្ហាញក្នុងសំណុំរឿង០០២ ដូចគ្នានឹងអង្គហេតុបង្ហាញក្នុងពាក្យសុំក្នុងសំណុំរឿង០០៣ និងជាអង្គហេតុស្ថិតក្នុងកន្លែងឧក្រិដ្ឋកម្មដែលស្ថិតក្រោមកិច្ចស៊ើបសួរទៀតផង។

៣៥. សរុបមក សេចក្តីសម្រេចបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍បានរំលោភគោលការណ៍ទូទៅអំពីភាពយុត្តិធម៌ និងជាពិសេស សិទ្ធិក្នុងការទទួលបានសច្ចភាពគតិយុត្តិ និងតម្លាភាព ស្របតាមវិធាន ២១(១) និង(១)(ក)នៃវិធានផ្ទៃក្នុង។

## ២. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍

## ស.ច.ស បានរំលោភវិធាន ២៣ស្ទួន(១)(ខ) និងមាត្រា ៣.២(ក) នៃ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ

## ក. ព្យសនកម្មជាលក្ខណៈបុគ្គលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋកម្ម

[២៩] អង្គការសហប្រជាជាតិ "តើវិធានច្បាប់ជាអ្វី?", អាចមើលនៅ ៖ http://www.unrol.org/article.aspx?article_id=3។

៣៦. ដូចបានបញ្ជាក់ខាងលើ[៣០] ស.ច.ស អះអាងថា "អ្នកដាក់ពាក្យសុំមិនបានធ្វើការបង្ហាញថា ព្យនសកម្មរូបរាងកាយ [sic] គឺជាផលវិបាក**ដោយផ្ទាល់**នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់"[៣១]។ ស.ច.ស អះអាងបន្តទៀតថា ៖

*"យោងតាមការប្រើប្រាស់ភាសាអង់គ្លេស ពាក្យថា "ផ្ទាល់" នៅក្នុងបរិបទនេះមានន័យថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ បានបង្កជាផលវិបាកដោយផ្ទាល់ដោយពុំមានទំនាក់ទំនងហេតុជាអន្តរការីណាមួយឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីនេះ ទំនាក់ទំនងអន្តរការីដែលបង្កឱ្យមានព្យសនកម្មផ្លូវចិត្តដែលអ្នកដាក់ពាក្យសុំបានលើកឡើងគឺជាការងារដោយបង្ខំដែលបានប្រព្រឹត្ត[redacted]។ ប្រសិនបើគ្មានទំនាក់ទំនងនេះទេ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នេះនឹងមិនអាចបង្កជាព្យសនកម្មចំពោះ[redacted]ឡើយ។ ហេតុដូច្នេះ ទម្រង់នៃទំនាក់ទំនងហេតុនិងបច្ច័យត្រូវបានគូសបំព្រួញដូចតទៅ ៖ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ - ការងារដោយបង្ខំដែលប្រព្រឹត្ត[redacted] - ព្យសនកម្មផ្លូវចិត្តដែលលើកឡើងដោយអ្នកដាក់ពាក្យសុំ"*[៣២] ។

៣៧. បើទោះបីជាខ្លួនទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ស.ច.ស បញ្ជាក់ថា ដីកាសម្រេចលើការទទួលយកពាក្យសុំក្នុងសំណុំរឿង ០០២ គឺជាសេចក្តីសម្រេចមិនត្រឹមត្រូវឡើយ ពីព្រោះវាមិនបានធ្វើការពន្យល់ ឬពិនិត្យលើលក្ខខណ្ឌតម្រូវអំពីពាក្យថា "ផ្ទាល់"ឡើយ" ហើយស្របនឹងការយល់ឃើញនេះដែរ "... មិនមានជាប់ពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធផ្ទាល់រវាងហេតុ និងបច្ច័យនោះឡើយ"[៣៣]។ ស.ច.ស លើកឡើងបន្តទៀតថា "ទោះបីក្នុងកាលៈទេសៈបែបណាក៏ដោយ ទង្វើករណ៍នានាដែលមានក្នុងសេចក្តីសម្រេចដែលធ្វើឡើងកាលពីពេលមុនៗ និងថែមទាំងក្នុងសំណុំរឿងខុសគ្នាផងដែរទៀត គ្មានលក្ខណៈចាប់បង្ខំតម្រូវឱ្យគោរពតាមនោះទេ ..."[៣៤]។

---

[៣០] មើលកថាខណ្ឌ ១៨ នៃបណ្តឹងឧទ្ធរណ៍នេះ។

[៣១] ក.ស.ច.ស "ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted]" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ D11/3។

[៣២] ដីកាសម្រេចរងការជំទាស់, កថាខណ្ឌ ៥។

[៣៣] ដូចខាងលើ, កថាខណ្ឌ ៧។

[៣៤] ដូចខាងលើ។

៣៨. ជាងនេះទៀត ស.ច.ស សម្រេចថា ការបកស្រាយរបស់ខ្លួន ៖

*"មិនផ្ទុយទៅនឹងកថាខណ្ឌ ៨ នៃគោលការណ៍ និងសេចក្តីណែនាំជាមូលដ្ឋានស្តីអំពីសិទ្ធិក្នុងការទទួលបានសំណង និងការជួសជុលការខូចខាតរបស់ជនរងគ្រោះនៃការរំលោភបំពានធំៗលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលចែងថា "ក្នុងករណីចាំបាច់ និងអនុលោមតាមច្បាប់ជាតិ ពាក្យថា "ជនរងគ្រោះ"ក៏រួមបញ្ចូលផងដែរនូវសាច់ញាតិខ្សែជិត ឬអ្នកនៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់ ..." ដោយហេតុថា វាមិនមែនជាការត្រឹមត្រូវនោះទេ ប្រសិនបើលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងផ្ទាល់ហេតុនិងបច្ច័យដែលមានចែងក្នុងវិធាន ២៣ស្ទួន ១(ខ) ត្រូវបាននិរាករណ៍ដោយសេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ ខណៈដែលថា ច្បាប់ជាតិ ជាក់ស្តែងមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៦៤ ក៏ទាមទារផងដែរនូវទំនាក់ទំនងផ្ទាល់នៃហេតុនិងបច្ច័យ"*[៣៥] ។

៣៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា "ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះ-រាជាណាចក្រកម្ពុជា" (CPC) បច្ចុប្បន្ន ត្រូវបានអនុម័តដោយរដ្ឋសភាជាតិនាខែមិថុនា ឆ្នាំ ២០០៧ នៅក្នុងអំឡុងកិច្ចប្រជុំពេញអង្គលើកទីមួយរបស់ អ.វ.ត.ក និងចូលជាធរមានចាប់តាំងពីខែ សីហា ឆ្នាំ ២០០៧។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងនៅក្នុងមាត្រា ៦១១ ថា៖

*"បទប្បញ្ញត្តិដូចតទៅនេះត្រូវទុកជានិរាករណ៍:*

- *រាល់បទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ មុនឆ្នាំ ១៩៩២*
- *(...)"*

បន្ថែមពីលើនេះទៀត មាត្រា ៦១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖

*"ក្រមនេះត្រូវអនុវត្តភ្លាម ចំពោះគ្រប់កិច្ចនីតិវិធីក្រោយក្រមនេះចូលជាធរមាន។"*

៤០. ដូច្នេះ ក្រមឆ្នាំ ១៩៦៤ ដែលសហចៅក្រមស៊ើបអង្កេតបានយកធ្វើជាសំអាង ពុំស្ថិតនៅជាធរមានទៀតទេ យ៉ាងហោចណាស់ក៏ចាប់តាំងពីឆ្នាំ ២០០៧ មកដែរ។

៤១. ទឡ្ហីករណ៍របស់សហចៅក្រមស៊ើបអង្កេតមានភាពចន្លោះប្រហោង ដោយសារតាមវិធីណាក៏ដោយ កង្វះនិយមន័យនៃពាក្យថា "ដោយផ្ទាល់" នៅក្នុងបញ្ញត្តិច្បាប់ មិនអាចឲ្យមានការចេញ

---

[៣៥] ដូចខាងលើ, កថាខណ្ឌ ៦។

សេចក្ដីសម្រេចដែលមានកំហុសឆ្គងនោះទេ។ ការពិត ចៅក្រមជាអ្នកសម្រេចលើការបកស្រាយបញ្ញត្តិនានា។

៤២. វិធានផ្ទៃក្នុង ២៣ *ស្ទួន*(១)(ខ) ចែងថា ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវ "បង្ហាញ ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត"។ ធាតុផ្សំសំខាន់បីយ៉ាងដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង្ហាញ និងត្រូវបញ្ជាក់រួមមាន៖ (១) អត្ថិភាពនៃព្យសនកម្ម។ (២) ផលវិបាកផ្ទាល់នៃបទឧក្រិដ្ឋ និង (៣) ការខូចខាតផ្ទាល់ខ្លួន។

៤៣. យោងតាមធាតុផ្សំទាំងបីយ៉ាងនេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានបង្ហាញអំពីអត្ថិភាពនៃព្យសនកម្មនៅក្នុងទម្រង់នៃការខូចខាតខាងផ្លូវចិត្ត។ ព្យសនកម្មនេះបានកើតឡើងជាផលវិបាកផ្ទាល់នៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តលើ[redacted]អ្នកដាក់ពាក្យសុំ។ ការពិតដែលគ្មានការសង្ស័យនោះគឺថា ម្ចាស់បណ្ដឹងឧទ្ធរណ៍បានបង្ហាញថា [redacted] បានរងនូវការខូចខាតផ្ទាល់ខ្លួននៅក្នុងទម្រង់នៃការខូចខាតខាងផ្លូវចិត្ត[៣៦]។

៤៤. វិធានផ្ទៃក្នុង ២៣ *ស្ទួន*(១)(ខ) រៀបចំតម្រូវឱ្យមានលក្ខណៈវិនិច្ឆ័យអំពីភាពអាចទទួលយកបានដើម្បីក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណីបានថា ការខូចខាតដែលជនរងគ្រោះបានទទួលរងជា "***ផលវិបាក ដោយផ្ទាល់ពីបទល្មើសនោះ***"។ ទោះបីជាយ៉ាងណាក៏ដោយ និយមន័យនេះមិនផ្ទុះបញ្ចាំងពីនិយមន័យនៃពាក្យថា "ជនរងគ្រោះ" នៅក្នុងសទ្ទានុក្រមរបស់វិធានផ្ទៃក្នុងដែលចែងថា "ជនរងគ្រោះ សំដៅទៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្មដោយសារអំពើ ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ"[៣៧] នោះទេ។

[៣៦] សូមមើលទំព័រទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ។

[៣៧] សទ្ទានុក្រមនៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៧)។ គិតត្រឹមពេលសរសេរវិធានផ្ទៃក្នុងថ្មីមិនទាន់ត្រូវបានផ្សាយជាសាធារណៈនៅឡើយទេ។

00726411



៤៥. នៅក្នុងការកំណត់បុរេលក្ខខណ្ឌដែលថា ព្យសនកម្មត្រូវតែជាផលវិបាក*ផ្ទាល់* ពីបទឧក្រិដ្ឋ/បទល្មើស អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ព្យសនកម្មអាចត្រូវបានទទួលរងដោយ "ជនរងគ្រោះផ្ទាល់ និងសាច់ញាតិជិតស្និទ្ធ"[៣៨]។

៤៦. ការបកស្រាយ (ដែលនៅមានន័យចង្អៀត) របស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នេះ គឺធ្វើឡើងយោងតាមគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ[៣៩] ពីព្រោះនិយមន័យនៃពាក្យថា "ជនរងគ្រោះ" មិនត្រូវបានកម្រិតតែចំពោះជនទាំងឡាយណា ដែលជាជនរងគ្រោះដោយផ្ទាល់នោះឡើយ។ ទោះបីជាឯកសារសំអាងផ្លូវច្បាប់ដែលត្រូវបានផ្តល់ឱ្យមានតែគោលការណ៍ណែនាំមួយក៏ដោយ វាជាប្រភពទូទៅមួយនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ICL) និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគ្រប់យុត្តាធិការជាតិដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលទាំងអស់[៤០] ដែលកម្រនឹងដោះស្រាយទៅលើករណីបទឧក្រិដ្ឋទ្រង់ទ្រាយធំ ហេតុដូច្នេះហើយមិនឆ្លុះបញ្ចាំងពីព្យសនកម្មដែលបានទទួលរងនៅក្នុងករណីបទឧក្រិដ្ឋទ្រង់ទ្រាយធំដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តលើសហគមន៍ទាំងមូល ឬប្រជាជាតិទាំងមូល[៤១]។

---

[៣៨] រឿងក្តីប្រឆាំង កាំង ហ្គេចអ៊ាវ សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សាលក្រម ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារលេខ E188 កថាខណ្ឌ៦៤៨។ វិធីសាស្ត្រចង្អៀតនៅក្នុងសំណុំរឿង ០០១ នេះ ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីប្តឹងសារទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូលដែលត្រូវបានចាត់ទុកថាមិនអាចទទួលយកបាន រីឯសេចក្តីសម្រេចមានភាពល្អប្រសើរ។

[៣៩] គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយគ្រប់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ រួមទាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

[៤០] ជាឧទាហរណ៍ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានយោងតែលើក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ដែលចែងនៅក្នុង ´395 (2) ប៉ុណ្ណោះ៖

" Die gleiche Befugnis steht Personen zu,

1. deren Kinder, Eltern, Geschwister, Ehegatten oder Lebenspartner durch eine rechtswidrige Tat getötet wurden (...)."(ការបកប្រែសេរី៖ "សិទ្ធិដូចគ្នា [ក្នុងការក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណី] ត្រូវបានផ្តល់ឱ្យជនទាំងឡាយណាដែលមានកូនចៅ ឪពុកម្តាយ បងប្អូនបង្កើត ប្តីប្រពន្ធ ឬដៃគូត្រូវគេសម្លាប់ដោយសារអំពើខុសច្បាប់")។

[៤១] សូមមើលសំណុំរឿង០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៤៤ ដល់ ៥០ និង ៧១ ដល់ ៨៣។ អង្គបុរេជំនុំជម្រះមានការយល់ឃើញទូលំទូលាយអំពីផលប៉ះពាល់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាន

## ខ. មាត្រា ៣.២ (គ) នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ

៤៧. ការបកស្រាយដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានប្រកាន់យក ត្រូវបានគាំទ្រយ៉ាងច្បាស់ដោយសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ដែលចែងថា៖

"ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ដើម្បីអាចឱ្យចាត់ទុកថាជាជនរងគ្រោះដែលស្ថិតនៅក្នុងគោលបំណង របស់ អ.វ.ត.ក៖

ក. អ្នកប្តឹងត្រូវជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មណា មួយស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក។

ខ. ដើម្បីត្រូវបានកំណត់ថាបានរងព្យសនកម្ម អ្នកប្តឹងត្រូវបង្ហាញ៖

- ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និង
- ជាផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនោះ ជាព្យសនកម្មដោយផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន។

គ. ការខូចខាតផ្លូវចិត្ត អាចគិតទាំងការស្លាប់ញាតិសន្តាន ដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ"។

៤៨. ដោយបានបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍ដោយសំអាងថា [redacted] មិនមែនជាជនរងគ្រោះដោយផ្ទាល់ទេនោះ សហចៅក្រមស៊ើបអង្កេតបានរំលោភ និង/ឬ បានធ្វើការបកស្រាយដោយភ័ន្តច្រឡំអំពីសេចក្តីណែនាំអនុវត្តដែលមានជាធរមាន។

៤៩. ដើម្បីឱ្យមានភាពពេញលេញ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមយោងទៅដល់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលផ្តល់ការណែនាំ លើសពីការណែនាំដែលបានផ្តល់ឱ្យដោយអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក ទៅទៀត។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានទទួលស្គាល់ជនរងគ្រោះដោយផ្ទាល់ និងជនរងគ្រោះដោយប្រយោល និងបានសម្រេចថា៖

---

បទឧក្រិដ្ឋជាច្រើន និងព្យសនកម្មដែលប៉ះពាល់លើប្រជាជន និងដែលអាច និងត្រូវតែមានទំនាក់ទំនងជាហេតុទៅនឹងជនជាប់ចោទ។

"បញ្ហាសម្រាប់ធ្វើការសម្រេចគឺបញ្ហាថាតើព្យសនកម្មដែលបានទទួលរងគឺជាការព្យសនកម្មផ្ទាល់ខ្លួនដែរឬទេ។ ប្រសិនបើជាព្យសនកម្មផ្ទាល់ខ្លួន **គេអាចភ្ជាប់ព្យសនកម្មនោះជាមួយជនរងគ្រោះផ្ទាល់ និងប្រយោលបាន។** បញ្ហាថាតើជនម្នាក់បានរងព្យសនកម្មជាលទ្ធផលនៃអំពើឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការដែរឬទេក៏ដោយ ហេតុដូច្នេះ ជនរងគ្រោះនៅចំពោះមុខតុលាការនឹងត្រូវបានពិចារណាសម្រេចដោយគិតដល់កាលៈទេសៈពិសេសផ្សេងៗ"[៤២]។ (សេចក្តីបញ្ជាក់បន្ថែម)

៥០. បន្ថែមពីលើនេះ វិធាន ៨៥(ក) នៃវិធាននីតិវិធី និងភស្តុតាង (RPE) របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិន* តម្រូវថា ព្យសនកម្មត្រូវតែជាផលវិបាក "**ដោយផ្ទាល់**" នោះទេ[៤៣]។ វិធាននេះស្របទៅនឹងនិយមន័យនៃពាក្យថា "ជនរងគ្រោះ" នៅក្នុងសន្ទានុក្រមរបស់វិធានផ្ទៃក្នុង ដែលដូចគ្នាបេះបិទទៅនឹងនិយមន័យនៃវិធាននីតិវិធី និងភស្តុតាង ។ ជាលក្ខណៈអន្តរជាតិ ព្យសនកម្មដែលបានទទួលរងមិនចាំបាច់ត្រូវតែជា "លទ្ធផល**ដោយផ្ទាល់**នៃការប្រព្រឹត្តបទឧក្រិដ្ឋណាមួយដែលស្ថិតនៅក្នុងយុត្តាធិការ" ទេ ប៉ុន្តែត្រូវតែជាព្យសនកម្មជាលក្ខណៈបុគ្គល។

៥១. តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (IACHR) បានផ្តល់ប្រាក់សំណងដល់សាច់ញាតិ និងដៃគូរបស់ជនរងគ្រោះ មិនត្រឹមតែនៅក្នុងករណីនៃការបាត់ខ្លួនប៉ុណ្ណោះទេ[៤៤] តែថែមទាំងនៅក្នុងករណីនៃការសម្លាប់មនុស្សផងដែរ[៤៥] និងការរំលោភលើសិទ្ធិមនុស្សធ្ងន់ធ្ងរផ្សេងទៀតនៅពេលដែលជន

---

[៤២] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06-1432 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ៣២។

[៤៣] វិធាន៨៥(ក) RPE នៃចែងថា៖ ""ជនរងគ្រោះ" មានន័យថាជារូបវន្តបុគ្គលដែលបានទទួលរងព្យសនកម្មជាលទ្ធផលនៃការប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ"។

[៤៤] រឿងក្តី *Velásquez Rodríguez តទល់នឹង ប្រទេសហុងឌូរ៉ាស់ (ការជួសជុលព្យសនកម្ម)* សាលក្រមថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៨៩ ស៊េរី គ លេខ៧ កថាខណ្ឌ៥០-៥២; សំណុំរឿង *Garrido និង Baigorria តទល់នឹង ប្រទេសអាហ្សង់ទីន (ការជួសជុលសំណង)* សាលក្រមថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៨ ស៊េរី គ លេខ៣៩ កថាខណ្ឌ៦២, ៦៣; រឿងក្តី *Blake តទល់នឹង ប្រទេសហ្គាតេម៉ាឡា* សាលក្រមថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ កថាខណ្ឌ៣៧; រឿងក្តី *Bámaca Velásquez តទល់នឹង ប្រទេសហ្គាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០២ ស៊េរី គ លេខ៩១ កថាខណ្ឌ៣៣-៣៦។

[៤៥] រឿងក្តី *Aloeboetoe តទល់នឹង ប្រទេសស៊ូរីណាម (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស៊េរី គ លេខ១៥ កថាខណ្ឌ៧១; រឿងក្តី *Panel Blanca តទល់នឹង ប្រទេសហ្គាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី

រងគ្រោះមិនបានស្លាប់ ឬបាត់ខ្លួន[៤៦]។ តុលាការ IACHR ពិចារណាឃើញថា គេអាចសន្មតបានថា ឪពុកម្តាយ កូនចៅ បងប្អូនបង្កើត និងដៃគូរបស់ជនរងគ្រោះផ្ទាល់ បានបំពេញលក្ខខណ្ឌកំណត់ទាំងអស់នេះ ហើយអ្នកទាំងនេះត្រូវតែត្រូវបានចាត់ទុកថាជាជនរងគ្រោះដោយប្រយោល[៤៧]។

៥២. ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺថា គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ បានកំណត់និយមន័យនៃពាក្យថា "ជនរងគ្រោះ" ក្នុងគោលការណ៍ ៤(៨) ដូចខាងក្រោម៖

> "... ជនរងគ្រោះគឺជាបុគ្គលដែលទទួលរងព្យសនកម្មជាលក្ខណៈបុគ្គលផង និងជាលក្ខណៈរួមគ្នាផង រួមទាំងព្យសនកម្មខាងរាងកាយ ឬខាងផ្លូវចិត្ត ការឈឺចាប់ផ្លូវចិត្ត ការបាត់បង់ផ្នែកសេដ្ឋកិច្ច ឬការខូចខាតនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ... ក្នុងករណីសមស្រប និងដោយអនុលោមតាមច្បាប់ក្នុងប្រទេសផង ពាក្យថា "ជនរងគ្រោះ" ក៏បានរាប់បញ្ចូលផងដែរ នូវក្រុមគ្រួសារផ្ទាល់ ឬអ្នកនៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់..."[៤៨]។

៥៣. សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំទាំងលើអង្គច្បាប់ ទាំងលើអង្គហេតុ នៅពេលធ្វើការសន្និដ្ឋានថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនមែនជា "ជនរងគ្រោះ" នោះទេ។ ជាការសន្និដ្ឋាន ពុំមាន

---

២៥ ខែ ឧសភា ឆ្នាំ ២០០១ ស៊េរី គ លេខ៧៦ កថាខណ្ឌ៨៥, ៨៦; រឿងក្តី *កុមារតាមចិញ្ចើមថ្នល់ តទល់នឹង ប្រទេសហ្គាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០១ ស៊េរី គ លេខ៧៧ កថាខណ្ឌ៦៨; រឿងក្តី *Juan Humberto Sánchez តទល់នឹង ប្រទេសហុងឌូរ៉ាស់* ស៊េរី គ លេខ៩ សាលក្រម ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៣ កថាខណ្ឌ១៥២។

[៤៦] រឿងក្តី *Loayza Tamayo តទល់នឹង ប្រទេសប៉េរូ (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស៊េរី គ លេខ៤២ កថាខណ្ឌ៩២។

[៤៧] រឿងក្តី *Blake តទល់នឹង ប្រទេសហ្គាតេម៉ាឡា (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ កថាខណ្ឌ៣៧[ឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់អ្នកបាត់ខ្លួន ដោយគ្មានភ័ស្តុតាងផ្សេងពីនេះ]; រឿងក្តី *Loayza Tamayo តទល់នឹង ប្រទេសប៉េរូ (ការជួសជុលសំណង)* សាលក្រម ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស៊េរី គ លេខ៤២ កថាខណ្ឌ៩២ [មនុស្សទាំងអស់ដែលមានចំណងគ្រួសារជិតស្និទ្ធ ពោលគឺជាកូន ឪពុកម្តាយ និងបងប្អូនប្រុសស្រី]; រឿងក្តី *Juan Humberto Sánchez តទល់នឹង ប្រទេសហុងឌូរ៉ាស់* សាលក្រមថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៣ ស៊េរី គ លេខ៩៩ កថាខណ្ឌ១៥២; រឿងក្តី *អ្នកជំនួញ ១៩ នាក់ តទល់នឹង ប្រទេសកូឡុំប៊ី* សាលក្រម ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០៤ ស៊េរី គ លេខ១០៩ កថាខណ្ឌ២៤៩ [កូន គូស្រករ ឪពុកម្តាយ និងបងប្អូនបង្កើត]។

[៤៨] គោលការណ៍៤(៨) គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ (សូមមើលជើងទំព័រ១២)។ គោលការណ៍មូលដ្ឋាន (សូមមើលជើងទំព័រ១១) ចែងពីនិយមន័យដូចគ្នាត្រង់មាត្រា ក(២)។

មូលដ្ឋានគតិយុត្តិស្របតាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ឬការគាំទ្រនៅក្នុងការអនុវត្តជាក់ស្តែងជាអន្តរជាតិ ឬនៅក្នុងយុត្តិសាស្ត្រ សម្រាប់ធ្វើការបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍ឡើយ ពីព្រោះ [redacted]បណ្តឹងឧទ្ធរណ៍បានបង្ហាញច្បាស់លាស់ហើយថា [redacted]បានទទួលរងព្យសនកម្ម ដែលជាផលវិបាកផ្ទាល់នៃបទឧក្រិដ្ឋដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ ដីកាដែលរងការជំទាស់របស់សហចៅក្រមស៊ើបអង្កេតហាក់ដូចជាបង្កើតឡើងដោយកត្តាទាំងឡាយក្រៅពីការបកស្រាយច្បាប់ត្រឹមត្រូវ និងការអនុវត្តច្បាប់ និងវិធានដោយត្រឹមត្រូវ និងបានរំលោភយ៉ាងច្បាស់លាស់លើវិធានផ្ទៃក្នុង ២៣ ស្ទួន(១)(ខ), មាត្រា ៣.២(គ) នៃសេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមរបស់ជនរងគ្រោះ និងគោលការណ៍ ៤(៨) នៃគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ។ ហេតុដូច្នេះ ដីកានេះគួរតែត្រូវបានច្រានចោល ទុកជាមោឃៈ រីឯម្ចាស់បណ្តឹងឧទ្ធរណ៍ គួរតែត្រូវបានផ្តល់ឱ្យនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើការអនុវត្តវិធាន និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធដោយត្រឹមត្រូវ។

## ៣. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍

***សហចៅក្រមស៊ើបអង្កេតបានរំលោភលើវិធានផ្ទៃក្នុង ២១(១), ២១(១)(គ), ២៣ ស្ទួន (១) គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ និងបានធ្វើលើសពីអំណាចរបស់ខ្លួន ដោយបានបដិសេធពាក្យសុំដោយផ្អែកលើមូលដ្ឋានជាជម្រើសមួយទៀតថាមិនបានបំពេញតាមបទដ្ឋាននៃការបង្ហាញភស្តុតាង***

៥៤. ជាជម្រើសម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេតបានចាត់ទុកពាក្យសុំថាមិនអាចទទួលយកបានទេ ដោយផ្អែកលើមូលដ្ឋានថា ការទាមទាររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលពាក់ព័ន្ធទៅនឹងព្យសនកម្មដែល[redacted]បានទទួលរង មិនបានបំពេញតាមបទដ្ឋាននៃការបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ទេ។ សហចៅក្រមស៊ើបអង្កេតបានយោងលើបទដ្ឋាននៃការបង្ហាញភស្តុតាងនៃវិធានផ្ទៃក្នុង ២៣ ស្ទួន (១) ដែលបានចែងថា៖

"នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ"[៤៩]។

៥៥. សហចៅក្រមស៊ើបអង្កេតបានប្រកាសពីមូលដ្ឋានជាជម្រើស សម្រាប់ធ្វើការបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដូចខាងក្រោម៖

*"ទោះបីជាយ៉ាងណាក៏ដោយ ការអះអាងរបស់អ្នកដាក់ពាក្យសុំដែលថា ការឈឺចាប់ និង ការអាណិតអាសូរដែល [redacted] ទទួលរងអស់រយៈពេល ៣៤ឆ្នាំមកនេះ ចំពោះទុក្ខវេទនា និងសុខភាពទ្រុឌទ្រោមរបស់ [redacted] (ជា [redacted] ត្រូវបានគេបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ជាមួយ) [redacted] ទទួលរងក្នុងរយៈកាល ០៣ ខែ នៃការបង្ខំឱ្យធ្វើការងារ នៅតែស្ថិតនៅក្នុងចិត្តរបស់ [redacted] នៅឡើយ។ ការណ៍នេះត្រូវបានកត់សម្គាល់ដោយសហចៅក្រមស៊ើបអង្កេត ប៉ុន្តែវាមិនអាចត្រូវបានចាត់ទុកថា "ទំនងជាការពិត" ឡើយ ជាពិសេសចំពោះការណ៍ដែលថា ការឈឺចាប់ និងការអាណិតអាសូរទាំងនោះត្រូវបានជំនួសដោយទុក្ខសោកថ្មីបន្ថែមទៀត ដោយការបាត់ខ្លួនរបស់ [redacted] ក្នុងពេលក្រោយមក និងការសម្លាប់នៅមន្ទីរស២១ ដូច្នេះធ្វើឱ្យ [redacted] អាចរសាយអំពីការនឹករលឹកនឹកឃើញអំពីការឈឺចាប់ និងការអាណិតអាសូរទាំងនោះ។*

*ទោះបីជាការចោទប្រកាន់នេះត្រូវបានចាត់ទុកយ៉ាងរឹងមាំថា ទំនងជាមិនមានការពិតក៏ដោយ ក៏មិនមានការច្រានចោលនូវលទ្ធភាពដែលថា វាត្រូវបានធ្វើឡើងដោយជំនឿនខុសឆ្គងរបស់តតិយជនណាម្នាក់"*[៥០] ។

## ក. ការរំលោភលើវិធានផ្ទៃក្នុង ២៣ ស្ទួន(១)

៥៦. ទោះបីជាបទដ្ឋាននៃការបង្ហាញភស្តុតាងដូចបានឆ្លុះបញ្ចាំងនៅក្នុងវិធានផ្ទៃក្នុង ២៣ ស្ទួន(១) ត្រូវយកទៅធ្វើការបកស្រាយក៏ដោយ ការបកស្រាយច្បាប់តម្រូវឱ្យមានបទដ្ឋានត្រឹមត្រូវដែលអាចត្រូវបានពិនិត្យដោយបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតខកខាន

---

[៤៩] ដីកាសម្រេច, កថាខណ្ឌ ៩។

[៥០] ដីកាសម្រេច, កថាខណ្ឌ៩។

មិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការយល់ឃើញថា ការលើកឡើងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ "ត្រូវបានពិចារណាឃើញថាមានភាពមិនពិតប្រាកដ" នោះទេ[៥១]។

៥៧. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតហាក់ដូចជាគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ ដោយមិនបានយោងលើអង្គហេតុណាមួយ ដែលធ្វើឱ្យមានការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអំពីការខកខានដែលបានអះអាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការបំពេញតាមបទដ្ឋាននៃការបង្ហាញភស្តុតាងនោះទេ ដោយមិនយល់ដឹងពីម្ចាស់បណ្តឹងឧទ្ធរណ៍ និងដោយមិនស្ថិតនៅក្នុងតួនាទីសមស្របដើម្បីធ្វើការវាយតម្លៃប្រភេទបុគ្គលផ្ទាល់ខ្លួន និងកម្រិតនៃការឈឺចាប់ ដូចជា មានការយល់ដឹងត្រឹមត្រូវអំពីចិត្តវិទ្យា ឬជំនាញខាងចិត្តវិទ្យា នោះឡើយ។ ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតថា កម្រិតនៃការបង្ហាញភស្តុតាងមិនត្រូវបានបំពេញ និងថា ការលើកឡើងអំពីការឈឺចាប់ និងព្យសនកម្ម គឺ "មានភាពមិនពិតប្រាកដ"នោះ គឺជាការភ័ន្តច្រឡំ។

៥៨. ពុំមានគ្រូពេទ្យចិត្តវិទ្យា អ្នកជំនាញចិត្តវិទ្យា ឬអ្នកជំនាញខាងការប៉ះទង្គិចផ្លូវចិត្តណាម្នាក់ នឹងធ្វើការសន្និដ្ឋានយ៉ាងទូលំទូលាយ និងលឿនបែបនេះ ដោយគ្មានព័ត៌មានលម្អិតដែលពាក់ព័ន្ធអំពីការឈឺចាប់ជាពិសេសនេះ និងរោគសញ្ញារបស់បុគ្គល ឬការយល់ដឹងពីព្យសនកម្មដែលបានទទួលរងនោះឡើយ។

៥៩. សហចៅក្រមស៊ើបអង្កេតបានបកស្រាយវិធានផ្ទៃក្នុង ២៣ *ស្ទួន*(១) ដោយភ័ន្តច្រឡំ នៅពេលធ្វើការអះអាងថា ការឈឺចាប់នោះ "នឹងត្រូវបានជំនួសដោយរឿងថ្មីៗទៀត... ដូច្នេះធ្វើឱ្យ [redacted] អាចរសាយអំពីការនឹករលឹកនឹកឃើញអំពីការឈឺចាប់នោះ"។ ការសន្និដ្ឋាននេះបានផ្អែកលើទស្សនៈយល់ឃើញមិនត្រឹមត្រូវ មិនមានវិជ្ជាជីវៈ និងមិនសមស្រប អំពីការប៉ះទង្គិចផ្លូវចិត្ត ដោយគ្មានមូលដ្ឋានណាមួយតាមវិទ្យាសាស្ត្រ ឬសំអាងហេតុនោះឡើយ។ សហចៅក្រមស៊ើបអង្កេតបានធ្វើលើសពីអំណាច និងសមត្ថកិច្ចរបស់ខ្លួនជាចៅក្រមយ៉ាងច្បាស់លាស់ណាស់ ដែលខ្លួនមិនមែនជាគ្រូពេទ្យចិត្តវិទ្យា ជាអ្នកជំនាញចិត្តវិទ្យា ឬជាអ្នកជំនាញ ខាងការប៉ះទង្គិចផ្លូវចិត្តនោះទេ តែជាអ្នកមានតួនាទីអនុវត្តច្បាប់ចំពោះអង្គហេតុនានា។

៦០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ការប៉ះទង្គិចផ្លូវចិត្តមានលក្ខណៈបុគ្គល និងហាក់ដូចជាមានការខុសប្លែកពីគ្នារវាងបុរស និងស្ត្រី ទោះជាមានការចងចាំអំពីការប៉ះ

[៥១] ដីកាសម្រេច, កថាខណ្ឌ៩។

ទង្គិចផ្លូវចិត្តតាមវិធីណា និងក្នុងវិសាលភាពណាក៏ដោយ[៥២]។ អ្នកជំនាញនានាពិចារណា ឃើញថា "មានការទទួលស្គាល់កើនឡើងផងដែរថា កត្តានានាក្រៅពីភាពធ្ងន់ធ្ងរនៃហេតុការណ៍ នោះផ្ទាល់ អាចមានផលប៉ះពាល់ធំបំផុតលើគុណភាពនៃការចងចាំ (ឧទាហរណ៍ តើហេតុការណ៍ នោះត្រូវបានគេនឹកគិតពីវាញឹកញាប់ប៉ុណ្ណា)"[៥៣]។ បទពិសោធន៍ការប៉ះទង្គិចផ្លូវចិត្តនៅក្នុងស្ថានភាព នៃបទឧក្រិដ្ឋច្រើន គឺខុសពីបទពិសោធន៍ការប៉ះទង្គិចផ្លូវចិត្តនៅក្នុងស្ថានភាពបទឧក្រិដ្ឋដែលមិន មានចំនួនច្រើន"ធម្មតា"។ អ្នកជំនាញទាំងឡាយបានពណ៌នាអំពីបទពិសោធន៍នៃការរំលោភលើសិទ្ធិ មនុស្សតទៅទៀតថា ជាការប៉ះទង្គិចផ្លូវចិត្តតាមលំដាប់លំដោយ ឬជាការបន្តភាពតានតឹងផ្នែក អារម្មណ៍តទៅទៀត[៥៤]។ ការលៃលកដោះស្រាយស្ថានភាពធ្ងន់ធ្ងរទាំងអស់នេះ អាចត្រូវបានវាយ តម្លៃតែតាមរយៈអ្នកជំនាញដែលពោរពេញដោយបទពិសោធន៍ប៉ុណ្ណោះ បន្ទាប់ពីបានពិនិត្យមើល សារតារទាំងមូល និងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកនៅរស់រានមានជីវិត។

៦១. លើសពីនេះទៀត ដោយអះអាងថា ការលើកឡើងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ "មិនមានភាពពិត ប្រាកដ" សហចៅក្រមស៊ើបអង្កេតចោទប្រកាន់ជនរងគ្រោះ និងអ្នកនៅរស់រានមានជីវិតដោយ ប្រយោលថាបាននិយាយភូតកុហក។ ប្រហែលជាដើម្បីដាក់ចេញនូវការអះអាងដែលមិនគួរឲ្យ ជឿបាន និងមិនអាចការពារបាននេះ សហចៅក្រមស៊ើបអង្កេតបន្តជាមួយនឹងការប៉ាន់ស្មានរបស់ ខ្លួនថា ការអះអាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍អាចផ្អែកលើ "ការណែនាំដែលមិនសមរម្យរបស់ តតិយជន"។ គ្មានអ្វីសង្ស័យទេ ការធ្វើបែបនេះគឺសំដៅប្រឆាំងនឹងតំណាងផ្លូវច្បាប់របស់[redacted] បណ្តឹងឧទ្ធរណ៍ដែលបានដាក់ទម្រង់បែបបទព័ត៌មានជនរងគ្រោះក្នុង[redacted]ផ្ទាល់។

---

[៥២] លោក Stephen Porter និង Angela R. Birt តើការចងចាំដែលប៉ះទង្គិចផ្លូវចិត្តមានលក្ខណៈពិសេសឬ? ការប្រៀបធៀប លក្ខណៈចងចាំដែលប៉ះទង្គិចផ្លូវចិត្តជាមួយនឹងការចងចាំអំពីបទពិសោធន៍ជីវិតផ្សេងទៀត នៅក្នុងចិត្តវិទ្យានៃដំណើរការខួរក្បាល ដែលបានអនុវត្ត 15:S101-117(2001)។ សូមមើលផងដែរ Silove, D. (ឆ្នាំ ១៩៩៩): ផលប៉ះពាល់ផ្លូវចិត្តអំពីការធ្វើទារុណ កម្ម, ការរំលោភលើសិទ្ធិមនុស្សជាច្រើន និងការប៉ះទង្គិចផ្លូវចិត្តរបស់ជនភៀសខ្លួន: ឆ្ពោះទៅក្របខណ្ឌនៃគំនិតដែលបានបញ្ចូល គ្នា។ នៅក្នុង៖ ទស្សនាវដ្តីស្តីពីជម្ងឺវង្វេងវង្វាន់ និងជម្ងឺផ្លូវចិត្ត ១៨៧(៤): ២០០-២០៧។ សូមមើល ខាងលើ ឯកសារសំអាង ផ្លូវច្បាប់ទីមួយ ត្រង់ទំព័រ S102។

[៥៣] សូមមើល ខាងលើ ឯកសារសំអាងផ្លូវច្បាប់ទីមួយ ត្រង់ទំព័រ S102។

[៥៤] Silove ជើងទំព័រលេខ ៥២ និង Hans Keilson (ឆ្នាំ ១៩៧៩) "Sequentielle Traumatisierung bei Kindern" ការស្រាវ ជ្រាវជាមូលដ្ឋានអំពីជនរងគ្រោះ Holocaust។

៦២. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការជំទាស់យ៉ាងខ្លាំងទៅនឹងការប៉ាន់ស្មានរបស់សហចៅក្រមស៊ើបអង្កេត និងអះអាងថា ពុំមានការរំលោភលើភារកិច្ច និងកាតព្វកិច្ចរបស់មេធាវីចំពោះកូនក្ដីរបស់ខ្លួននោះទេ។

៦៣. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថែមទៀតថា ការវាយតម្លៃ *ហួសពីសមត្ថកិច្ចរបស់ខ្លួន* របស់សហចៅក្រមស៊ើបអង្កេតអំពីផលប៉ះពាល់ផ្លូវចិត្តលើម្ចាស់បណ្ដឹងឧទ្ធរណ៍នៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តលើ [redacted] មិនប្រើប្រាស់ជាមូលដ្ឋានជាជម្រើសត្រឹមត្រូវសម្រាប់ធ្វើការបដិសេធពាក្យបណ្ដឹងរដ្ឋប្បវេណី [redacted] នោះទេ ហេតុដូច្នេះការវាយតម្លៃនេះត្រូវតែធ្វើការបដិសេធចោល។

៦៤. ជាការសន្និដ្ឋាន សហចៅក្រមស៊ើបអង្កេតបានបកស្រាយវិធាន ២៣ ស្ទួន (១) ដោយភ័ន្តច្រឡំ ដោយប៉ាន់ស្មានអំពីបញ្ហាដែលលើសពីការយល់ដឹងរបស់ខ្លួន និងដោយមិនផ្ដល់នូវមូលហេតុត្រឹមត្រូវ និងលម្អិតពាក់ព័ន្ធនឹងបញ្ហាថាតើសហចៅក្រមស៊ើបអង្កេតអាចធ្វើការសន្និដ្ឋានបែបនេះបានដោយរបៀបណា។

### ខ. ការរំលោភលើវិធានផ្ទៃក្នុង ២១(១) និង ២១(១)(គ) និងគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំនានា

៦៥. វិធានផ្ទៃក្នុង ២១(១) និង ២១(១)(គ) ឆ្លុះបញ្ចាំងពីគោលការណ៍នៃភាពយុត្តិធម៌ និងកំណត់កាតព្វកិច្ចឱ្យ អ.វ.ត.ក ធ្វើការបកស្រាយវិធានផ្ទៃក្នុងដែលជានិច្ចកាលពាក់ព័ន្ធទៅនឹងការការពារផលប្រយោជន៍ (*ដែលនៅក្នុងចំណោមវិធានទាំងនោះ*) របស់ជនរងគ្រោះ និងឱ្យគោរពសិទ្ធិរបស់ជនរងគ្រោះ។

៦៦. សំអាងហេតុដែលថា ការឈឺចាប់របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ដោយសារការធ្វើការងារដោយបង្ខំរបស់ [redacted] គឺ "មិនមានភាពពិតប្រាកដ"នោះ គឺជាការប្រមាថមើលងាយដល់ជនរងគ្រោះដែលបានទទួលរងព្យសនកម្មធ្ងន់ធ្ងរពីបទឧក្រិដ្ឋលើសាច់ញាតិដែលជិតជាងគេ។ ការអះអាងរបស់សហចៅក្រមស៊ើបអង្កេតថា ខ្លួនមិនជឿលើការអះអាងដែលធ្វើឡើងដោយ [redacted] បណ្ដឹងឧទ្ធរណ៍ស្ដីអំពីអង្គហេតុ ឬកម្រិតនៃការឈឺចាប់ផ្ទាល់ខ្លួន ដោយគ្មានមូលដ្ឋានណាមួយថែមទៀតទេនោះ បង្កើតបានជាការបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតជឿថា [redacted] បណ្ដឹងឧទ្ធរណ៍កំពុងតែភូតកុហក។ សំអាងហេតុទាំងអស់នេះធ្វើឱ្យមានការអាប់ឱនកិត្តិយសរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍

ដែលជាការរំលោភលើគោលការណ៍នៃការគោរព និងការការពារសិទ្ធិរបស់ជនរងគ្រោះ ដូចដែលបានបញ្ជាក់នៅក្នុងវិធានផ្ទៃក្នុង[៥៥]។

៦៧. ប្រសិនបើសហចៅក្រមស៊ើបអង្កេតប្រកាន់យកនូវវិធីសាស្ត្រស្រដៀងគ្នា ចំពោះគ្រប់ជនរងគ្រោះ "ដោយប្រយោល" នៃបទឧក្រិដ្ឋទាំងអស់ (សមាជិកគ្រួសារផ្ទាល់របស់ជនរងគ្រោះផ្ទាល់) វានឹងក្លាយជាការរើសអើងដោយប្រយោល លើជនរងគ្រោះដែលបានទទួលរងព្យសនកម្មជាបុគ្គល និងដោយផ្ទាល់ ដែលកើតចេញមកពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តលើសាច់ញាតិដែលជិតជាងគេ។ មកទល់នឹងពេលនេះ វាពិតជាកើតមានដូច្នេះមែន គឺកើតមានបែបនេះចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លោក Rob Hamill និងនៅពេលនេះ គឺកើតមានចំពោះ [redacted]។

៦៨. លើសពីនេះទៀត គោលការណ៍ VI (១០) នៃគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំចែងថា៖

> *"ជនរងគ្រោះគួរតែត្រូវបានទទួលការប្រព្រឹត្តដោយមនុស្សធម៌ និងការគោរពចំពោះសេចក្ដីថ្លៃថ្នូរ និងសិទ្ធិមនុស្ស និងវិធានការសមស្របគួរត្រូវបានធ្វើឡើងដើម្បីធានាដល់សុវត្ថិភាព សុខុមាលភាពផ្នែករាងកាយ និងផ្លូវចិត្ត និងជីវិតឯកជនរបស់ជនរងគ្រោះ ក៏ដូចជារបស់ក្រុមគ្រួសាររបស់ជនរងគ្រោះផងដែរ។ រដ្ឋគួរតែធ្វើការធានាតាមលទ្ធភាពថា ច្បាប់ជាតិចែងថាជនរងគ្រោះដែលបានទទួលរងអំពើហិង្សា ឬការប៉ះទង្គិចផ្លូវចិត្ត គួរតែទទួលបាននូវផលប្រយោជន៍ពីការពិចារណាពិសេស និងការយកចិត្តទុកដាក់ដើម្បីជៀសវាងកុំឱ្យពួកគាត់រងការប៉ះទង្គិចផ្លូវចិត្តម្ដងទៀតនៅក្នុងដំណើរការនីតិវិធីច្បាប់ និងរដ្ឋបាលដែលត្រូវបានរៀបចំដើម្បីផ្ដល់ភាពយុត្តិធម៌ និងសំណង"*។

៦៩. មានការទទួលស្គាល់ក្នុងចំណោមអ្នកជំនាញផ្នែកជនរងគ្រោះ[៥៦]ថា ការទទួលស្គាល់ថាជាជនរង-គ្រោះដែលបានទទួលរងព្យសនកម្មជាក់លាក់ គឺជាសមាសភាគសំខាន់នៃនីតិវិធីតុលាការ។

៧០. ប្រសិនបើរឿងមួយមានភាពច្បាស់លាស់ រឿងនោះគឺថា ជនរងគ្រោះដោយសារបទឧក្រិដ្ឋ - មិនថាជាជនរងគ្រោះដោយផ្ទាល់ ឬដោយប្រយោលនោះទេ - សុទ្ធតែចង់ឱ្យគេជឿជាក់លើខ្លួន។

---

[៥៥] សូមមើល វិធានផ្ទៃក្នុង ២១(១) និង (១) (គ)។

[៥៦] សូមមើល សេចក្ដីលម្អិតថែមទៀត , Intervict, វិទ្យាស្ថានជនរងគ្រោះវិទ្យាអន្តរជាតិ សាកលវិទ្យាល័យ Tilburg សូមបើកមើល http://www.tilburguniversity.edu/research/institutes-and-research-groups/intervict/។

មួយផ្នែកនៃមូលហេតុដែលស្ថិតនៅពីក្រោយការរក្សាការស្ងៀមស្ងាត់មិនបញ្ចេញឱ្យដឹងរឿងសំខាន់ - សម្រាប់ជនរងគ្រោះដែលមិននិយាយអំពីព្យសនកម្មរបស់ខ្លួន- គឺជាការភ័យខ្លាចគេមិនជឿជាក់លើខ្លួន។ នៅក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៣ [redacted] បានរៀបរាប់ឡើងវិញជាថ្មីម្ដងទៀតដោយក្លាហានអំពីរឿងរ៉ាវរបស់[redacted]។ ដោយ លើកឡើងថា ពាក្យសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍គឺ "មានភាពមិនពិតប្រាកដ" ដោយគ្មានមូលដ្ឋានអង្គហេតុ ឬមូលដ្ឋានផ្សេងទៀតណាមួយ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ពីការមិនយកចិត្តទុកដាក់លើគោលការណ៍នៃការទទួលស្គាល់ចំពោះម្ចាស់បណ្ដឹងឧទ្ធរណ៍ ហើយបើធ្វើដូច្នេះករណីនេះក៏កើតឡើងចំពោះគ្រប់ជនរងគ្រោះទាំងអស់ដែលមានស្ថានភាពដូច[redacted]បណ្ដឹងឧទ្ធរណ៍នេះដែរ។

៧១. ដោយបន្ថែមថា ការឈឺចាប់នេះមានការពាក់ព័ន្ធទៅនឹង "[redacted]ដែលបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" របស់[redacted]បណ្ដឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតបង្ហាញពីបុរេវិនិច្ឆ័យដែលខុសបន្ថែមទៀត និងបង្ហាញពីការគ្មានសាវតារវិជ្ជាជីវៈស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ បន្ថែមពីលើនេះទៀត សហចៅក្រមស៊ើបអង្កេតបង្ហាញពីការដែលគ្មានការយល់ចិត្ត និងបង្ហាញពីការមិនយកចិត្តទុកដាក់ចំពោះការឈឺចាប់របស់ជនរងគ្រោះផងដែរ។

៧២. មិនគ្រាន់តែជាការសង្ស័យរបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះទេ ដោយគ្មានលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ ដោយគ្មានវិជ្ជាជីវៈ និងការ បង្ហាញពីការគ្មានចំណេះដឹងរបស់សហចៅក្រមស៊ើបអង្កេតអំពីការប៉ះទង្គិចផ្លូវចិត្ត មតិយោបល់ទាំងឡាយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត បានរំលោភលើគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្ដីអំពីថាតើជនរងគ្រោះគួរតែទទួលបានការប្រព្រឹត្តបែបណា *ដែលនៅក្នុង គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំនោះ* គេត្រូវប្រព្រឹត្តចំពោះជនរងគ្រោះដោយ "ការគោរពសេចក្ដីថ្លៃថ្នូរ សុខុមាលភាពផ្នែករាងកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ ដើម្បីជៀសវាងកុំឱ្យពួកគាត់រងការប៉ះទង្គិចផ្លូវចិត្តម្ដងទៀត"។

៧៣. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា ការបញ្ជាក់ហេតុផលនៅក្នុងជម្រើសទីមួយគឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើវិធានផ្ទៃក្នុង ២១(១) ១៩ (គ) និងគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ ព្រមទាំងបង្កើតបានជាការភ័ន្តច្រឡំលើអង្គច្បាប់។

## ៤. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍

**ស.ច.ស បានរំលោភបំពានលើវិធាន២១(១) វិធាន២១(១)(គ) វិធាន២៣(១) នៃវិធានផ្ទៃក្នុង គោលការណ៍ជាសារវន្តនៃដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ជនរងគ្រោះ និងសិទ្ធិទទួលបាន សេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវក្នុងការបដិសេធពាក្យសុំ ជាជម្រើសមួយទៀត ដោយសារភាពចាំបាច់ឲ្យមានការកាត់សេចក្តីដោយឆាប់រហ័ស និងការទទួលបានសិទ្ធិជាដើមបណ្តឹង រដ្ឋប្បវេណីក្នុងសំណុំរឿង០០១ និង០០២**

៧៤. ស.ច.ស បានបដិសេធពាក្យសុំជាជម្រើសទីពីរ និងទីបី ដោយសារ៖

> *"(១) "ការទទួលយកពាក្យសុំនេះនឹងមិនស្របទៅនឹងគោលការណ៍នៃភាពឆាប់រហ័សនៃនីតិវិធី" ដែលមានចែងក្នុងវិធាន២១(៤) ឡើយ ដោយហេតុថា អំពើឧក្រិដ្ឋដែលប្រព្រឹត្តនៅព្រលានយន្តហោះកំពង់ឆ្នាំងដែលបានចោទប្រកាន់ គឺជាផ្នែកនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ហើយ*
>
> *(២) [redacted]ដាក់ពាក្យសុំកំពុងអនុវត្តសិទ្ធិជាដើមបណ្តឹងជារដ្ឋប្បវេណីនៅក្នុងសំណុំរឿងនោះផងដែរ និងថែមទាំងបានអនុវត្តសិទ្ធិ[redacted]ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងមន្ទីរស២១ ក្នុងអំឡុងពេលនៃដំណើរការជំនុំជម្រះសំណុំរឿង០០១ ផងដែរ""*[៥៧]។

៧៥. សំអាងហេតុដែលជាជម្រើសទីបីនៃការបដិសេធនេះ គឺជាមូលដ្ឋានទូទៅមួយដែលត្រូវយកមកអនុវត្តចំពោះអ្នកដាក់ពាក្យសុំដែលបានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីរួចក្នុងសំណុំរឿងណាមួយក្នុងចំណោមសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក។ បើតាមការយល់ដឹងរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានតែដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០១ និង/ឬ ០០២ ទេដែលបានដាក់ពាក្យសុំសម្រាប់សំណុំរឿង០០៣ (និង០០៤)[៥៨]។ ហេតុនេះ

---

[៥៧] ដីកាដែលរងការជំទាស់, កថាខណ្ឌ១០។

[៥៨] គេអាចសន្និដ្ឋានពីអង្គហេតុនោះថា អង្គការក្រៅរដ្ឋាភិបាលទំនងជាមិនអាចបំពេញការងារផ្សព្វផ្សាយក្នុងសំណុំរឿង០០៣ និង ០០៤ ដើម្បីជូនដំណឹងដល់ប្រជាជនបានទេ ហើយតុលាការមិនអាចបំពេញការងារនេះបានដែរ។ ហេតុនេះ មានតែដើមបណ្តឹងរដ្ឋប្បវេណីដែលមានស្រេចទេដែលបានដាក់ពាក្យសុំក្នុងសំណុំរឿង០០៣ និង០០៤។ បន្ថែមទៅទៀត ដោយសារពុំមានព័ត៌មានទាក់ទិននឹងសំណុំរឿងនេះផងនោះ មានលទ្ធភាពតិចតួចណាស់ដែលអង្គការក្រៅរដ្ឋាភិបាលអាចផ្តល់ព័ត៌មានដល់ជនរងគ្រោះពីបញ្ហានេះបាន។ ផ្ទុយទៅវិញ តុលាការទាំងមូលបានចូលរួមធ្វើឱ្យកាន់តែមានការលំបាកសម្រាប់ជនរងគ្រោះក្នុងការដាក់ពាក្យសុំដោយសារទម្រង់បែបបទនៃការដាក់ពាក្យសុំត្រូវលុបចេញពីគេហទំព័រ នៅពេលកាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ពាក្យសុំកំពុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាន

សំអាងហេតុនៃការបដិសេធនេះ គឺជាសំអាងហេតុទូទៅមួយ ដើម្បីបដិសេធអ្នកដាក់ពាក្យសុំ**ទាំងអស់**នាពេលនេះ ដោយមិនទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង០០៣ (និង ០០៤)។ អាចនិយាយម្យ៉ាងទៀតបានថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣ និង០០៤ នឹងជា*ការស៊ើបអង្កេតដោយពុំមានដើមបណ្តឹងរដ្ឋប្បវេណី* ហើយ ប្រសិនបើកិច្ចដំណើរនីតិវិធីរបៀបនេះទៅដល់ដំណាក់កាលសវនាការវិញ នោះក៏ក្លាយជា*សវនាការដោយពុំមានដើមបណ្តឹងរដ្ឋប្បវេណី*ដែរ។

៧៦. នីតិវិធីនេះជាការរំលោភបំពានពិតប្រាកដ និងធ្ងន់ធ្ងរទៅលើខ្លឹមសារ និងចេតនារបស់វិធានផ្ទៃក្នុង ក្រុមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបទដ្ឋានអន្តរជាតិ។ ការដកអ្នកដាក់ពាក្យសុំចេញ ដោយសារ (១).មូលហេតុនៃកិច្ចដំណើរការនីតិវិធីឆាប់រហ័ស (ដោយគ្មានតុល្យភាពរវាងកម្មវត្ថុនេះ និងសិទ្ធិរបស់ជនរងគ្រោះ) និង (២).ការចូលរួមរបស់អ្នកទាំងនោះនៅក្នុងសំណុំរឿងផ្សេងៗទៀត គ្មានសំអាងតាមផ្លូវច្បាប់ និងសំដៅទៅដល់ការបញ្ចូលដោយខុសច្បាប់នូវលក្ខណៈវិនិច្ឆ័យថ្មីៗ ដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី[៥៥]។ ស.ច.ស បានរំលោភបំពានដោយចេតនាទៅលើច្បាប់ជាធរមាន និងវិធានផ្ទៃក្នុង ដោយបដិសេធអ្នកដាក់ពាក្យសុំជាជម្រើសដោយផ្អែកលើមូលដ្ឋាននេះ។ ជាថ្មីម្តងទៀត ការណ៍ដែល ស.ច.ស មិនទទួលស្គាល់អ្នកដាក់ពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីដែលមានធម្មានុរូប ដែលស្របតាមលក្ខណៈវិនិច្ឆ័យនៃការទទួលយកស្របច្បាប់ បង្ហាញថា ស.ច.ស កំពុងធ្វើដំណើរឆ្ពោះទៅកាន់ការច្រានចោលសំណុំរឿង០០៣ (និង០០៤) ហើយ។

៧៧. វិធីសាស្ត្រដែលពុំមានសំអាងហេតុច្បាស់លាស់នេះ ក៏ជាការរំលោភបន្ថែមទៀតទៅលើគោលការណ៍សច្ចភាពគតិយុត្តិ ដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលធ្លាប់ត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង០០១ ត្រូវបានសាកសួរ ហើយ ស.ច.ស ក៏<u>បានអញ្ជើញ</u>ឱ្យចូលរួមក្នុងសំណុំរឿង០០២ បន្ទាប់ពីបានចូលរួមក្នុងសំណុំរឿង០០១ រួចមកហើយនោះ។

៧៨. ជាមួយនឹងសំអាងហេតុជាជម្រើសនៃការបដិសេធនេះ (បើតាមទស្សនៈរបស់ ស.ច.ស គឺអាចនៅតែឯងបាន ប្រសិនបើ អ.ប.ជ មិនទទួលយកសំអាងហេតុដទៃទៀត) ស.ច.ស មិនបានអនុវត្តឱ្យ

---

ខិតជិតមកដល់។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានតវ៉ាលើបញ្ហានេះទៅផ្នែកកិច្ចការសាធារណៈ និងអង្គភាពគាំទ្រជនរងគ្រោះ។

[៥៥] ចៅក្រមត្រូវបកស្រាយច្បាប់ តែមិនត្រូវបានអនុញ្ញាតឱ្យបន្ថែមធាតុផ្សំបង្កើតថ្មីទេ។

បានត្រឹមត្រូវតាមវិធានផ្ទៃក្នុងដែលបានចែងច្បាស់ពីលក្ខណៈវិនិច្ឆ័យ ដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ ការចូលរួមនៅក្នុងសំណុំរឿង០០២ ដែលទីតាំងឧក្រិដ្ឋកម្មដដែល នឹងត្រូវពិនិត្យឡើងវិញ ឬការណ៍ដែលធ្លាប់បានចូលរួមរួចមកហើយនៅក្នុងសំណុំរឿង០០១ ដែលទីតាំងឧក្រិដ្ឋកម្មមួយទៀតត្រូវបានដាក់បញ្ចូលនោះ មិនបានធ្វើឲ្យការចូលរួមរបស់ពួកគេទៅក្នុងសំណុំរឿង ០០៣ និង/ឬ ០០៤ អស់សុពលភាពនោះទេ។ ចំណុចដែលបានលើកឡើងដោយ ស.ច.ស មិនមែនជាទឡ្ហីករណ៍ដែលមានសុពល ឬជាលក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់ដែលមានអត្ថិភាព សម្រាប់ការចេញដីកាសម្រេចលើការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

៧៩. សំអាងហេតុនៃជម្រើសនេះគឺជា "ការបន្ថែម" ទៅលើសេចក្តីសម្រេចដែលមិនអាចទទួលយកបាន ហើយវាជាការរំលោភបំពានយ៉ាងច្បាស់ទៅលើសិទ្ធិជាសារវន្តរបស់ជនរងគ្រោះ (១).ទទួលបានសវនាការត្រឹមត្រូវ (២).ទទួលបានការពិត (៣).ទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព រួមទាំងការទទួលបានសំណងផង។ ស.ច.ស បានដកអ្នកដាក់ពាក្យសុំចេញទាំងស្រុងពីការអនុវត្តនូវសិទ្ធិទាំងនេះក្នុងសំណុំរឿង០០៣ ដែលនឹងមិនអាចទទួលបានដំណោះស្រាយដោយការចូលរួមក្នុងសវនាការមួយដោយមាន (ក).ជនជាប់ចោទផ្សេងទៀត និង/ឬ សាច់រឿងព្រហ្មទណ្ឌដែលផ្សេងគ្នា នោះទេ។

៨០. បន្ថែមទៅទៀត "សំអាងហេតុ" នេះមិនសមហេតុសមផលទាល់តែសោះ ដែលធ្វើឲ្យការបដិសេធនេះប្រែក្លាយទៅជាសេចក្តីសម្រេចដែលមានកំហុសធ្ងន់ ដោយផ្អែកលើមូលដ្ឋាននៃការខកខានមិនបានផ្តល់នូវសំអាងហេតុ (សមស្រប និងគ្រប់គ្រាន់) ដែលនេះជាការរំលោភបំពានដល់វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលលិខិតុបករណ៍ទាំងពីរនេះតម្រូវថា សេចក្តីសម្រេចត្រូវមានសំអាងហេតុត្រឹមត្រូវ[៦០]។

## ៥. មូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍

---

[៦០] សូមមើលជាឧទាហរណ៍សំណុំរឿង០០២, បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តកែប, ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D392/3/1, កថាខណ្ឌ ៥០-៦៣។

**ស.ច.ស រំលោភបំពានលើវិធាន១៤(១) វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង មាត្រា១០ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក មាត្រា៥(២) និង(៣) នៃកិច្ចព្រមព្រៀង និងគោលការណ៍របស់អង្គការសហប្រជាជាតិប្រឆាំងនឹងនិទណ្ឌភាព ដោយខកខានមិនបានធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងឯករាជ្យនូវសំណុំរឿង០០៣**

៨១. ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ គឺផ្អែកលើការខកខានរបស់ ស.ច.ស មិនបានស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងឯករាជ្យទៅលើអង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ដែលសហព្រះរាជអាជ្ញាបានបញ្ជូនទៅ។

៨២. បើតាមមាត្រា៥(២) និង(៣) នៃកិច្ចព្រមព្រៀង មាត្រា១០ នៃច្បាប់ស្តីពី អ.វ.ត.ក និងវិធាន១៤(១) និងវិធាន៥៥(៥) នៃវិធានផ្ទៃក្នុង (សហ)ចៅក្រម(ស៊ើបអង្កេត) "ត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតបានឡើយ" ហើយ "ពួកគេត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ និងឯករាជ្យ"។

៨៣. នៅខែ កញ្ញា ឆ្នាំ ២០០៤ លោក **កូហ្វី អាណាន** (Kofi Annan) ដែលពេលនោះជាអគ្គលេខាធិការអង្គការសហប្រជាជាតិបានតែងតាំងអ្នកជំនាញឯករាជ្យមួយរូបឱ្យធ្វើបច្ចុប្បន្នភាពទៅលើគោលការណ៍របស់អង្គការសហប្រជាជាតិស្តីពីការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស តាមរយៈការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព[៦១]។ អ្នកជំនាញរូបនោះបានចេញរបាយការណ៍មួយ និងគោលការណ៍មួយចំនួនដែលបានធ្វើបច្ចុប្បន្នភាពរួច (គោលការណ៍ស្តីពីនិទណ្ឌភាព) នៅពេលគាត់បានបញ្ចប់អាណត្តិការងាររយៈពេលមួយឆ្នាំរបស់ខ្លួន[៦២]។ គោលការណ៍ទាំងនេះបានបញ្ជាក់ច្បាស់នូវសិទ្ធិនានាដែលត្រូវបានធានាចំពោះជនរងគ្រោះដោយអំពើឃោរឃៅរួមមាន៖

---

[៦១] *សូមមើល*សេចក្តីប្រកាសព័ត៌មានរបស់អង្គការសហប្រជាជាតិ, "អគ្គលេខាធិការតែងតាំងអ្នកជំនាញឯករាជ្យដើម្បីធ្វើបច្ចុប្បន្នភាពទៅលើគោលការណ៍មួយចំនួនដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព" ("Secretary-General Appoints Independent Expert to Update Set of Principles to Combat Impunity") ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៤ នៅគេហទំព័រ៖ http://www.unhchr.ch/huricane/huricane.nsf/0/F851F48DECAB6A26C1256F0F005714AF?opendocument។

[៦២] ឯកសារអង្គការប្រជាជាតិលេខ E/CN.4/2005/102,, ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស៖ និទណ្ឌភាព (Promotion and Protection of Human Rights: Impunity), របាយការណ៍របស់អ្នកជំនាញឯករាជ្យដើម្បីធ្វើបច្ចុប្បន្នភាពទៅលើគោលការណ៍មួយចំនួនដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើនិទណ្ឌភាព, Diane Orentlicher, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ នៅគេហទំព័រ៖ http://daccess-dds-ny.un.org/doc/UNDOC/GEN/G05/111/03/PDF/G0511103.pdf?OpenElement និងឯកសារបន្ថែម

(១) សិទ្ធិដឹងពីការពិត

(២) សិទ្ធិទទួលបានយុត្តិធម៌ និង

(៣) សិទ្ធិទទួលបានសំណង ដោយមានការធានាថានឹងមិនកើតមាននូវអំពើឃោរឃៅសាជាថ្មីទេ[៦៣]។

៨៤. ស.ច.ស បានរំលោភបំពានទៅលើគោលការណ៍ទាំងនេះ និងថែមទាំងរំលោភបំពានដល់តួនាទីជាក់លាក់របស់ខ្លួនផង ដោយសារពួកគេបានទទួលសំណុំរឿង០០៣ (និង០០៤) ហើយបានបន្តធ្វើឱ្យខកខានមិនស៊ើបអង្កេតឱ្យបានត្រឹមត្រូវទៅលើអង្គហេតុនៅក្នុងសំណុំរឿង០០៣ ដែលពាក់ព័ន្ធដោយផ្ទាល់ចំពោះអ្នកដាក់ពាក្យសុំតែម្តង។ ការស្ទាក់ស្ទើររបស់ ស.ច.ស មិនស៊ើបអង្កេតឱ្យហួសពីសំណុំរឿង០០២ មានរឿងរ៉ាវវែងឆ្ងាយណាស់ ហើយទង្វើបែបនេះត្រូវបានជម្រុញដោយការចូលជ្រៀតជ្រែកផ្នែកនយោបាយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា[៦៤] និងដោយសារមូលហេតុនានាដែលមិនបានបញ្ចេញឱ្យដឹង ទាក់ទិននឹងការមិនស៊ើបអង្កេតពីសំណាក់ ស.ច.ស អន្តរជាតិ។

៨៥. ចាប់តាំងពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ មក នៅពេល ស.ច.ស បានទទួលជាលើកដំបូងនូវសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ និងទីបី[៦៥] រយៈពេលជាង ២០ ខែ បានកន្លងផុតទៅ ដោយពុំមានបើកកិច្ចស៊ើបសួរឱ្យបានត្រឹមត្រូវទេ។ នៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១ ស.ច.ស បានជូនដំណឹងជាសាធារណៈថា មិនមានការចុះស៊ើបអង្កេតដល់មូលដ្ឋានទេ ហើយ "ភារកិច្ចបច្ចុប្បន្នគឺការ

---

គោលការណ៍មួយចំនួនដែលបានធ្វើបច្ចុប្បន្នភាពរួច សម្រាប់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្សតាមរយៈការធ្វើសកម្មភាពដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើនិទណ្ឌភាព។

[៦៣] ត្រូវបានដកស្រង់ចេញពីរបាយការណ៍របស់អង្គការ OSJI, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ ត្រង់ទំព័រ១, សូមមើលជើងទំព័រ ១៦។

[៦៤] "ចំណុចនេះស៊ីសង្វាក់គ្នាទៅនឹងផែនការមួយដែលរាយការណ៍ដោយចៅក្រម ក្នុងការបញ្ចប់សំណុំរឿងទាំងពីរដែលកំពុងដំណើរការនៅតុលាការ ដែលសំណុំរឿងទាំងពីរនេះពាក់ព័ន្ធនឹងជនរងគ្រោះជាង ១០០.០០០ នាក់។ ពុំមានការចាប់ខ្លួន ពុំមានការប្រកាសពីការចោទប្រកាន់អ្វីទាំងអស់" នៅក្នុង "ការបិទសំណុំរឿងដែលអាចឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់សាលាក្តីខ្មែរក្រហម" ('Closure of Cases may Reflect Official View of KR'), ព្រឹត្តិប័ត្រព័ត៌មានខេមបូឌាដេលី, ចេញផ្សាយថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រមុខ, ដោយលោក Douglas Gillison។

[៦៥] សូមមើលព័ត៌មានសាធារណៈនៅគេហទំព័រ៖ http://www.eccc.gov.kh/en/articles/acting-international-co-prosecutor-requests-investigation-additional-suspects, ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩។

ពិនិត្យ និងវិភាគលើឯកសារនានាដែលមាននៅក្នុងសំណុំរឿង ជាពិសេសឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿង០០១ និង០០២”[៦៦]។ មួយរយៈខ្លីក្រោយពីការប្រកាសនេះ ការបិទការស៊ើបអង្កេតក៏ត្រូវបានប្រកាសជាសាធារណៈដែរ។ គេអាចសន្និដ្ឋានបានថា តាមរយៈពេលវេលាដ៏ខ្លីចាប់ពីការប្រកាសថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១ និងការប្រកាសបិទការស៊ើបអង្កេតថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ (រយៈពេលមិនដល់បីខែផង) មិនមានការចុះស៊ើបអង្កេតដល់មូលដ្ឋានណាមួយត្រូវបានអនុវត្តឡើយ។

៨៦. ដើម្បីបន្ថែមទម្ងន់ទៅលើចំណុចនេះទៀត “ការស៊ើបអង្កេត” របស់ ស.ច.ស ទទួលរងនូវការប៉ះពាល់តាំងពីដំបូងដោយសារតែការ “មិនចុះហត្ថលេខា” នៅលើដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងសំណុំរឿង០០៣ និង០០៤ របស់សហចៅក្រមស៊ើបអង្កេតជាតិ លោកចៅក្រម **យូ ប៊ុនឡេង**[៦៧]។ ក្រោយពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១០ បានកំណត់កាលបរិច្ឆេទចុងក្រោយ សម្រាប់សហចៅក្រមជាតិដែលជាដៃគូ ចុះហត្ថលេខាលើដីកាចាត់ឱ្យស៊ើបសួរជំនួសរួចមក នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១០ យោងតាមអ្នកនាំពាក្យផ្នែកកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិគឺលោក ឡារស៍ អូលសិន (Lars Olsen) “កិច្ចស៊ើបអង្កេតជាលើកដំបូងសម្រាប់សំណុំរឿង០០៣ និង០០៤ ត្រូវបានធ្វើឡើងនៅថ្ងៃសុក្រ [ទី ៤ ខែ មិថុនា ឆ្នាំ ២០១០] ក្នុងទម្រង់ជាដីកាចាត់ឱ្យស៊ើបសួរជំនួសជាសម្ងាត់ [...] ដែលបានចុះហត្ថលេខាដោយ[សហចៅក្រមស៊ើបអង្កេត] *ទាំងពីររូប*”[៦៨]។

---

[៦៦] សូមមើលសេចក្តីថ្លែងការណ៍សាធារណៈនៅគេហទំព័រ៖ http://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-case-files-003-and-004,ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១។

[៦៧] អនុសារណៈផ្ទៃក្នុងរបស់ ក.ស.ច.ស របស់លោកចៅក្រម **យូ ប៊ុនឡេង** ផ្ញើរជូនលោកចៅក្រម Marcel Lemonde ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១១ “Dossiers 003 et 004” (ការបកប្រែក្រៅផ្លូវការពីភាសាបារាំង មកជាភាសាអង់គ្លេស)។

[៦៨] លោក Douglas Gillison “តុលាការខ្មែរក្រហមចាប់ផ្តើមការស៊ើបអង្កេតទៅលើជនសង្ស័យនៃរបបខ្មែរក្រហមចំនួនប្រាំនាក់ថ្មីទៀត” (‘KRT Begins Investigation of Five New Regime Suspects’), ព្រឹត្តិប័ត្រព័ត៌មានឌឹកម្ពុជាដេលី, ចេញផ្សាយថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០, ទំព័រ២៦ (មានការគូសបញ្ជាក់បន្ថែម)។ លោករាជ សម្បត្តិ អ្នកនាំពាក្យរបស់សាលាក្តីបានចេញនូវសេចក្តីថ្លែងការណ៍មួយដែលប្រកាសថា លោកចៅក្រម **យូ ប៊ុនឡេង** មិនពាក់ព័ន្ធជាមួយដីកាចាត់ឱ្យស៊ើបសួរជំនួសនោះទេ ហើយបានបញ្ជាក់ថា របាយការណ៍ [របស់សារព័ត៌មាន] ដែលនិយាយពីការចុះហត្ថលេខាលើឯកសារនេះ ដែលរបាយការណ៍

៨៧. ភ្លាមៗបន្ទាប់ពីនោះគឺមានចម្លើយតបមួយ៖ "អ្នកនាំពាក្យក្រសួងមហាផ្ទៃ [នៃរាជរដ្ឋាភិបាលកម្ពុជា] ឧត្តមសេនីយឯក **ខៀវ សុភ័គ** បានបញ្ជាក់ឡើងវិញនូវការជំទាស់ [របស់រាជរដ្ឋាភិបាលកម្ពុជា] ចំពោះការស៊ើបអង្កេតថ្មីៗ [...]" ដោយលោកបានដកស្រង់នូវការព្រមានរបស់សម្តេច **ហ៊ុន សែន** ពីភាពវឹកវរ។ "*មានការកាត់ទោសមេដឹកនាំកំពូលៗតែប្រាំរូបប៉ុណ្ណោះ។ មិនមែនប្រាំមួយនាក់ទេ គឺប្រាំនាក់ប៉ុណ្ណោះ។* តុលាការត្រូវតែធានានូវស្ថិរភាព និង សន្តិភាពនៅក្នុងប្រទេស។ យើងមិនចង់បានជម្លោះ និងអស្ថិរភាពផ្ទៃក្នុងនោះឡើយ"[៦៩]។

៨៨. នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ បន្ទាប់ពីបានគូសចោលនូវហត្ថលេខាដែលបានចុះរួចមក លោកចៅក្រម **យូ ប៊ុនឡេង** បានជូនដំណឹងដល់ដៃគូអន្តរជាតិរបស់លោកថា លោកលែងយល់ស្របជាមួយនឹងបេសកកម្មនេះទៀតហើយ។ "បន្ទាប់ពីបានពិចារណាយ៉ាងស៊ីជម្រៅ និងយ៉ាងយកចិត្តទុកដាក់ទៅលើបញ្ហានេះរួចមក ខ្ញុំគិតថាវាមិនទាន់ដល់ពេលសម្រាប់ការធ្វើសកម្មភាពសម្រាប់សំណុំរឿង០០៣ និង០០៤ នោះឡើយ"[៧០]។

៨៩. នៅខែ មិថុនា ឆ្នាំ ២០១០ អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌នៃវិទ្យាស្ថានសង្គមសេរី (OSJI) ដែលជាអ្នកឃ្លាំមើលសាលាក្តីដ៏មានកេរ្តិ៍ឈ្មោះមួយបានចេញនូវរបាយការណ៍មួយដែលវាយតម្លៃលើការ "មិនចុះហត្ថលេខា"នេះដូចខាងក្រោម៖

> *"លោកចៅក្រម **យូ ប៊ុនឡេង** ជាដំបូងបានចុះហត្ថលេខាអនុញ្ញាតឱ្យមានការស៊ើបអង្កេតទាំងនេះ ប៉ុន្តែក្រោយមកបន្តិចបានលុបចោលការយល់ព្រមរបស់លោក បន្ទាប់ពីដីកានេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយអ្នកនាំពាក្យក្រសួងមហាផ្ទៃបានបញ្ជាក់សារជាថ្មីជាសាធារណៈថា "មានតែមេដឹកនាំកំពូលចំនួនប្រាំរូបប៉ុណ្ណោះត្រូវទទួលការកាត់ទោស"។ លោកចៅក្រម **យូ ប៊ុនឡេង** បានលើកយក "ស្ថានភាពបច្ចុប្បន្ននៃសង្គមកម្ពុជា" មកធ្វើជាមូលហេតុសម្រាប់ការច្រានចោលនូវការយល់ព្រមចំពោះការស៊ើបអង្កេតណាមួយទៅលើសំណុំរឿង។ លោកបានចង្អុលបង្ហាញថា ការស៊ើបអង្កេតទៅលើសំណុំរឿងណាមួយ នឹងត្រូវពិចារណាម្តងទៀតបន្ទាប់ពីចេញ*

---

នេះផ្អែកលើព័ត៌មានដែលផ្តល់ឱ្យដោយលោក Lars Olsen អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិ ជាព័ត៌មានដែលមិនមានមូលដ្ឋាន។

[៦៩] *ដូចជើងទំព័រខាងលើ។*

[៧០] អនុស្សរណៈផ្ទៃក្នុងសម្រាប់ក.ស.ច.ស របស់លោកចៅក្រម **យូ ប៊ុនឡេង** ផ្ញើជូនលោកចៅក្រម Marcel Lemonde ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ "Dossiers 003 et 004" (ការបកប្រែក្រៅផ្លូវការពីភាសាបារាំង មកជាភាសាអង់គ្លេស)។

*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ [សម្រាប់សំណុំរឿង០០២]។* ***ទាំងនេះគឺជាសនិទានកម្មផ្នែកនយោបាយយ៉ាងជាក់ច្បាស់។***

*នៅពេលដែលគិតដល់ការជំទាស់ជារៀងរហូតមករបស់រាជរដ្ឋាភិបាល ដែលមិនអនុញ្ញាតឲ្យមានការបន្តសំណុំរឿង០០៣ និង០០៤ ទៅមុខដោយឯករាជ្យនោះ ចំណុចនេះវាគាំទ្រដល់ការសន្និដ្ឋានដែលថា ការជ្រៀតជ្រែកផ្នែកនយោបាយ ធ្វើឲ្យប៉ះពាល់ដោយមិនសមហេតុផលដល់សេចក្តីសម្រេចចំពោះសំណុំរឿង"*[៧១]។

៩០. នៅថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ "ពាក់ព័ន្ធនឹងបញ្ហាពេលវេលាសមស្របសម្រាប់ចំណាត់ការស៊ើបសួរ" និងថា "សម្រាប់រយៈពេលរហូតដល់ដំណាច់ឆ្នាំនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងបន្តដំណើរការងារនេះតែម្នាក់ឯង ដោយអនុលោមទៅតាមបញ្ញត្តិនៃវិធាន៧២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក"[៧២]។

៩១. អ្នកតាមឃ្លាំមើលបានយល់ឃើញថា "ការខ្វែងយោបល់គ្នានេះគឺស្របជាមួយនឹងការបង្ហាញជាចំហរចំពោះការស្នាក់ស្ទើររបស់រាជរដ្ឋាភិបាល ក្នុងការចោទប្រកាន់ទៅលើមេដឹកនាំនៃរបបខ្មែរក្រហមថ្មីបន្ថែម ពីលើមេដឹកនាំទាំងប្រាំនាក់ដែល[ស្ថិតក្នុងការឃុំឃាំង] រួចហើយ"[៧៣]។ ហើយ "ក្នុងពេលឥឡូវនេះលោកចៅក្រម **ម៉ារសែល ឡឺម៉ុង** (Marcel Lemonde) បានបន្តដំណើរការងារនេះដោយគ្មានការគាំទ្រពីសហការីជាតិរបស់គាត់ ក្នុងការស៊ើបអង្កេតទៅលើបទចោទដែល

---

[៧១] ក.ស.ច.ស "ការជ្រៀតជ្រែកផ្នែកនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ខែ កក្កដា ឆ្នាំ ២០១០ ដែលមាននៅគេហទំព័រ៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/political-interference-report-20100706 ទំព័រ២១ ដោយមានការគូសបញ្ជាក់បន្ថែម។

[៧២] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ដែលមាននៅ http://old.eccc.gov.kh/english/cabinet/press/156/PROCIJ%28JUne2010.pdf ។

[៧៣] Sebastian Strangio, "ចៅក្រមសាលាក្តីខ្មែរក្រហមខ្វែងគំនិតគ្នាក្នុងសំណុំរឿងបន្ទាប់" ('KRT judges divided on next cases'), កាសែតភ្នំពេញប៉ុស្តិ៍, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ១។

មានលក្ខណៈនយោបាយ ហើយដែលមន្ត្រីរាជរដ្ឋាភិបាលបានបញ្ជាក់រួចមកហើយថាមិនត្រូវបន្តទៅមុខឡើយ"[៧៤]។

៩២. បើទោះបីជាដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់សំណុំរឿង០០២ ត្រូវបានប្រកាសនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ក៏ដោយ ក៏មិនមានដំណើរការស៊ើបអង្កេតឲ្យបានត្រឹមត្រូវ ដូចជាការស៊ើបអង្កេតនៅតាមទីកន្លែងផ្ទាល់ ការស្តាប់ចម្លើយសាក្សី ជនរងគ្រោះ និងការសួរចម្លើយជនសង្ស័យនោះឡើយ។

៩៣. សហចៅក្រមស៊ើបអង្កេត មិនបានបំពេញតួនាទី ភារកិច្ច និងមុខងារផ្នែកច្បាប់របស់ខ្លួនស្របតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា៖

> *"រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ... ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ... សហចៅក្រមស៊ើបអង្កេតមានអំណាច ក្នុងការសួរចម្លើយជនសង្ស័យ ការស្តាប់ចម្លើយជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន ..."*[៧៥]។

សហចៅក្រមស៊ើបអង្កេតមិនបានដំណើរការកិច្ចស៊ើបសួរថ្មីនៅក្នុងសំណុំរឿង០០៣ ឡើយ ហើយ ស.ច.ស បានយោងតែទៅលើឯកសារសម្ភារៈដែលមានស្រាប់នៅក្នុងសំណុំរឿង០០១ និង០០២ ប៉ុណ្ណោះ។ សំណុំរឿង០០១ និង០០២ ទាក់ទិននឹងជនសង្ស័យប្រាំនាក់ផ្សេងទៀតទាំងស្រុង ហើយវិធីសាស្ត្ររបស់ ស.ច.ស ក្នុងការស៊ើបអង្កេតនេះ គឺជាការមិនសមហេតុផល ហើយមិនបានបង្ហាញនូវចេតនា ឬការជម្រុញណាមួយដល់ការអនុវត្តនូវមុខងាររបស់ខ្លួនឲ្យបានពេញលេញ ត្រឹមត្រូវ និងឯករាជ្យនោះឡើយ។ ស.ច.ស មិនបានធ្វើតាម "នីតិវិធីជាធរមាន" ដែលរួមមានការសួរយកចម្លើយជនសង្ស័យ និងជនរងគ្រោះ ការស្តាប់ចម្លើយសាក្សី និងការប្រមូលភស្តុតាងនោះឡើយ។ សហចៅក្រមស៊ើបអង្កេត មិនបានបំពេញនូវសកម្មភាពណាមួយក្នុងចំណោមសកម្មភាពទាំងអស់នេះឡើយ ដូច្នេះពួកគាត់មិនបានអនុវត្តនូវការទទួលខុសត្រូវខាងផ្លូវច្បាប់ក្នុងនាមជាសហចៅក្រមស៊ើបអង្កេតនោះឡើយ។

---

[៧៤] លោក Douglas Gillison, "មានសំណួរច្រើនជាចម្លើយ" ('More Questions than Answers'), ព្រឹត្តិប័ត្រព័ត៌មានខ្មែរកម្ពុជាដេលី, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០។

[៧៥] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា២៣ ទំព័រ៩។

៩៤. ការមិនធ្វើការស៊ើបអង្កេតឱ្យបានពេញលេញ ឬត្រឹមត្រូវនោះ វាហាក់ដូចជាជាប់ទាក់ទងផ្ទាល់ទៅនឹងសេចក្តីថ្លែងការណ៍ជាសាធារណៈដដែលៗរបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលរួមទាំងការថ្លែងក្នុងឱកាសជួបជាមួយលោក **បាន គីមូន** (Ban Ki-moon) អគ្គលេខាធិការអង្គការសហប្រជាជាតិដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជា កាលពីខែ តុលា ឆ្នាំ ២០១០ ថា៖ "សវនាការសំណុំរឿងទី២ របស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមខ្មែរក្រហម ដែលនឹងត្រូវចាប់ផ្តើមនៅដើមឆ្នាំក្រោយ គឺជាសវនាការសំណុំរឿងចុងក្រោយបង្អស់។ សម្តេច **ហ៊ុន សែន** បានបញ្ជាក់យ៉ាងច្បាស់ថា មិនអនុញ្ញាតឱ្យមានសំណុំរឿង០០៣ទេ"។ រដ្ឋមន្ត្រីក្រសួងការបរទេស ឯកឧត្តម **ហោ ណាំហុង** បានប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីមានជំនួបរវាងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាមួយសម្តេចនាយករដ្ឋមន្ត្រីថា "យើងត្រូវតែគិតអំពីសន្តិភាពនៅកម្ពុជា"[៧៦]។ អង្គការ OSJI បានវាយតម្លៃទៅលើសេចក្តីថ្លែងការណ៍ក្នុងពេលថ្មីៗនេះដូចខាងក្រោម៖

> *"ការជ្រៀតជ្រែកផ្នែកនយោបាយទៅក្នុងកិច្ចការរបស់តុលាការ យ៉ាងឥតលាក់លៀមបែបនេះ គឺពិតជាផ្ទុយទៅនឹងបទដ្ឋានជាមូលដ្ឋាននៃជំនុំជម្រះដោយយុត្តិធម៌"*[៧៧]

ហើយ

> *"ជាក់ស្តែង មន្ត្រីតុលាការកម្ពុជាមិនមានសេរីភាពក្នុងការដំណើរការនីតិវិធីដោយឯករាជ្យ ចំពោះការចោទប្រកាន់ដែលត្រូវទទួលរងការជំទាស់ជាចំហរ និងជាប្រចាំពីសំណាក់ [នាយករដ្ឋមន្ត្រី] បែបនេះឡើយ។ ជាការគួរឱ្យយល់បានថា មន្ត្រីតុលាការកម្ពុជាពិតជាភ័យខ្លាចមិនហ៊ានរឹងទទឹងជាចំហរ ប្រឆាំងនឹងបញ្ហាជាសាធារណៈរបស់ប្រមុខរដ្ឋនោះឡើយ"*[៧៨]។

---

[៧៦] របាយការណ៍របស់ AFP "នាយករដ្ឋមន្ត្រីកម្ពុជាបាននិយាយថា គ្មានសំណុំរឿងទី៣ សម្រាប់តុលាការខ្មែរក្រហមទេ" ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០, របាយការណ៍របស់អង្គការ "យុត្តិធម៌ដែលទាមទារឱ្យមានការសង្គ្រោះ" 'Salvaging Justice', មាននៅក្នុង៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/khmer-rouge-tribunal-20101110។

[៧៧] របាយការណ៍អង្គការ OSJI "ឯករាជ្យភាពរបស់តុលាការដែលទាមទារឱ្យមានការសង្គ្រោះ៖ តម្រូវការឱ្យមានផែនការដើម្បីបញ្ចប់ជាគោលការណ៍ ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមាននៅក្នុង http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/khmer-rouge-tribunal-20101110។

[៧៨] របាយការណ៍អង្គការ OSJI "ការវិវឌ្ឍន៍ថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ខែ ធ្នូ ឆ្នាំ ២០១០ ដែលមាននៅ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/cambodia-report-20101207/cambodia-khmer-rouge-report-20101207.pdf។

៩៥. ចៅក្រមកម្ពុជាមួយរូបនៅ អ.វ.ត.ក បានប្រាប់លោក ចេមស៍ ហ្គោលស្តូន (James Goldston) ដែលជានាយកប្រតិបត្តិនៃអង្គការ OSJI កាលពីដើមខែ កុម្ភៈ ឆ្នាំ ២០១០ ថា អ្វីដែលសំខាន់នោះគឺថា "តើយើងអាចថាតុលាការនេះថាជាតុលាការគំរូនៃយុត្តិធម៌ឯករាជ្យបានដោយរបៀបណា បើរដ្ឋាភិបាលមិនអនុញ្ញាតឱ្យយើងបំពេញការងាររបស់យើងបានផងនោះ?"[៧៩]។

៩៦. ឧទាហរណ៍ពាក់ព័ន្ធមួយទៀតអំពីការជ្រៀតជ្រែកដោយផ្ទាល់ពីសំណាក់រាជរដ្ឋាភិបាលទៅក្នុងកិច្ចការរបស់តុលាការ ក្នុងសំណុំរឿង០០២ គឺនៅពេលដែល ក.ស.ច.ស មិនអាចធ្វើការស្តាប់ចម្លើយសាក្សីសំខាន់ៗដែលបានទទួលការបង្គាប់បញ្ជាមិនឱ្យគោរពតាមដីកាកោះហៅរបស់តុលាការនោះ។ ក្រោយពីមានបណ្តឹងឧទ្ធរណ៍ពីសំណាក់មេធាវីការពារក្តី[៨០] ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានថ្លែងថា "បើទោះបីជា ក.ស.ច.ស ជាស្ថាប័នស៊ើបអង្កេតរបស់ អ.វ.ត.ក ក៏ដោយ តែ ក.ស.ច.ស បានបដិសេធជាច្រើនលើកច្រើនសារ មិនធ្វើការស៊ើបអង្កេតទៅលើបញ្ហានេះទេ [ការចោទប្រកាន់ពីការជ្រៀតជ្រែក]"។ ចៅក្រមអន្តរជាតិយល់ឃើញថា "យោបល់របស់ **ខៀវ សំផន** ធ្វើឱ្យយើងជឿថា មានហេតុផលគួរឱ្យជឿថា គាត់ ឬបុគ្គលដែលគាត់និយាយដោយជំនួសមុខឱ្យនោះ អាចប៉ុនប៉ងដោយចេតនាពិតប្រាកដ ក្នុងការគម្រាមកំហែង ឬបំភិតបំភ័យមន្ត្រីទាំង៦រូប ឬបើមិនដូច្នោះទេ ជ្រៀតជ្រែកលើការសម្រេចចិត្តរបស់មន្ត្រីទាំង៦រូបនោះ ទាក់ទងនឹងការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យមកផ្តល់សក្ខីកម្ម"[៨១]។

៩៧. បន្ថែមពីលើនេះទៀត ដោយសារតែការបិទទ្វារការិយាល័យអ្នកស៊ើបអង្កេត ហាក់ដូចជាខិតជិតមកដល់ ហើយអ្នកស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិបានទទួលការជូនដំណឹងថាកិច្ចសន្យាការងាររបស់ខ្លួន នឹងមិនត្រូវបន្តឱ្យលើសពីបំណាច់ឆ្នាំនេះឡើយ[៨២] មានមន្ត្រីផ្នែកច្បាប់ និងអ្នកស៊ើបអង្កេតអង្គការសហប្រជាជាតិចំនួនប្រាំមួយរូបបានចាកចេញពី ក.ស.ច.ស ចាប់ពីខែ មេសា

---

[៧៩] លោក James Goldston, "តុលាការកម្ពុជានៅត្រង់ផ្លូវបំបែក" ('Cambodia's Court at a Crossroads'), *Wall Street Journal*, ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១០។

[៨០] សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណុំសុំឱ្យកោះហៅសាក្សី ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D314/1/12, ទំព័រ២១។

[៨១] *ដូចជើងទំព័រខាងលើ*។

[៨២] Julia Wallace, "កិច្ចស៊ើបអង្កេតនៃសំណុំរឿង០០៣ បានឈានដល់ការបញ្ចប់" ('Case 003 investigation reaches conclusion'), ព្រឹត្តិប័ត្រព័ត៌មានខ្មែរកម្ពុជាដេលី, ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១១ ទំព័រ២។

ដល់ខែ មិថុនា ឆ្នាំ ២០១១[៨៣] ដោយសារពួកគេចង់បំពេញការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ ឬត្រូវចាកចេញពីបរិយាកាសការងារដែលដំណើរការខុសប្រក្រតី[៨៤]។ ចាប់តាំងពីពេលដែល ស.ច.ស អន្តរជាតិថ្មីចូលកាន់តំណែងពីថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០ មក ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ មិនបានដំណើរការទៅមុខឡើយ ផ្ទុយទៅវិញ ស.ច.ស អន្តរជាតិបច្ចុប្បន្ននេះបានចូលរួមជាមួយសមភាគីជាតិរបស់ខ្លួន ដោយសារមានមូលហេតុដែលមិនអាចដឹងបាន។ ប្រការនេះកាន់តែបង្ហាញច្បាស់ថា សំណុំរឿង០០៣ (និង០០៤) នឹងត្រូវបដិសេធចោលជាឯកច្ឆ័ន្ទមិនខានឡើយ។

៩៨. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានចេញសេចក្តីប្រកាសព័ត៌មានមួយឆ្លើយតបទៅនឹងការស៊ើបអង្កេតសម្រាប់សំណុំរឿង០០៣ ដោយបានគូសបញ្ជាក់ពីចេតនារបស់ខ្លួនក្នុងការស្វែងរកនូវការបំពេញកិច្ចស៊ើបសួរបន្ថែមទៀត[៨៥]។ សហព្រះរាជអាជ្ញាអន្តរជាតិបានមានប្រសាសន៍នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនថា អំពើឧក្រិដ្ឋ "មិនទាន់ត្រូវបានស៊ើបអង្កេតឱ្យបានពេញលេញនៅឡើយទេ" ហើយបានពោលបន្ថែមទៀតនៅតាមប្រព័ន្ធព័ត៌មាននាពេលបន្ទាប់មកទៀតថា ការស៊ើបអង្កេត "ជាច្រើនទៀត" នឹងត្រូវតែអនុវត្ត[៨៦]។

---

[៨៣] លោក Douglas Gillison, "មន្ត្រីអង្គការសហប្រជាជាតិទី៦ បានលាលែងចេញពីការិយាល័យចៅក្រមនៃសាលាក្តីខ្មែរក្រហម" ('6th UN Official resigns from KR Judges' office'), ព្រឹត្តិប័ត្រព័ត៌មានឌឹកម្ពុជាដេលី, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១១, ទំព័រ២៤។

[៨៤] លោក Douglas Gillison, "ក្រុមអ្នកច្បាប់អង្គការសហប្រជាជាតិដើរចេញពីសំណុំរឿងនៅសាលាក្តីខ្មែរក្រហមដែលកំពុងរាំងស្ទះ" ('UN Legal Team Walk out on Stymied KR Cases'), ព្រឹត្តិប័ត្រព័ត៌មានឌឹកម្ពុជាដេលី, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១។

[៨៥] សេចក្តីប្រកាសព័ត៌មាន៖ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងសំណុំរឿង០០៣, ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ នៅគេហទំព័រ៖ http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-case-file-003។

[៨៦] លោក Rob Carmichael, "ការជឿទុកចិត្តទៅលើសាលាក្តីក្រោមការគម្រាមកំហែង ដោយសារប្រមុខដឹកនាំសំណុំរឿងដែលមានចម្រូងចម្រាស់បានបិទសំណុំរឿងទាំងនេះ" ("Tribunal's Credibility Under Threat as Controversial Cases Head for Closure"), ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១ នៅគេហទំព័រ៖ http://www.robertcarmichael.net/Robert_Carmichael/Cambodia_Radio_News/Entries/2011/5/11_Tribunals_credibility_under_threat_as_controversial_cases_head_for_closure.html។

៩៩. ស.ច.ស បានច្រានចោលពាក្យសុំបំពេញកិច្ចស៊ើបសួរចំនួនបី ពីសហព្រះរាជអាជ្ញាអន្តរជាតិ។ នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធនោះ[៨៧]។ ទោះជាយ៉ាងណាក្តី សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសង្កេតឃើញថា ទោះបីអង្គបុរេជំនុំជម្រះសម្រេចទទួលយកសំណើ និងបង្គាប់ឱ្យ ក.ស.ច.ស ធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវចំពោះបញ្ហាទាំងនេះក៏ដោយ ក៏ទំនងជាលេចឡើងថា ការសម្រេចបិទការិយាល័យនេះត្រូវបានសម្រេចជាមុនរួចទៅហើយ។

១០០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញថា ស.ច.ស កំពុងធ្វើការ *ផ្ទុយពី* បេសកកម្មការងាររបស់ អ.វ.ត.ក ដែលនឹងបង្កើតជាយុត្តិសាស្ត្រនៃនិទណ្ឌភាពមួយដ៏មានគ្រោះថ្នាក់សម្រាប់អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋជាទ្រង់ទ្រាយធំ។ សកម្មភាពរបស់ ស.ច.ស បង្ហាញពីការប្រមាថ និងមាក់ងាយដល់កិច្ចដំណើរការតាមផ្លូវតុលាការ និងសិទ្ធិរបស់ជនរងគ្រោះ ជាការរំលោភបំពានដល់បទដ្ឋានអន្តរជាតិស្តីពីកិច្ចដំណើរការតាមផ្លូវតុលាការ និងសិទ្ធិរបស់ជនរងគ្រោះ។ ទង្វើនេះផ្ទុយពីទស្សនៈវិស័យរបស់ អ.វ.ត.ក ដែលត្រូវបានសង្ខេបនៅលើគេហទំព័ររបស់ អ.វ.ត.ក ថា៖

> *"តុលាការថ្មីហើយពិសេសនេះត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ប៉ុន្តែតុលាការនេះគឺឯករាជ្យម្ចាស់ការ មិនចំណុះអោយរាជរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិទេ ។ តុលាការនេះ គឺជាតុលាការកម្ពុជាដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ដែលនឹងអនុវត្តទៅតាមស្តង់ដារអន្តរជាតិ ។* ***តុលាការនេះ នឹងផ្តល់ជាគំរូតួនាទីថ្មីមួយសំរាប់ដំណើរការកាត់ក្តីនៅកម្ពុជា"***[៨៨]។

១០១. ជាងនេះទៀត ប្រសិនបើ អ.វ.ត.ក នឹងក្លាយជាតុលាការគំរូថ្មីមួយសម្រាប់ដំណើរការរបស់តុលាការនៅកម្ពុជា សកម្មភាពរបស់ ស.ច.ស ក្នុងសំណុំរឿង០០៣ បានធ្វើឱ្យគំរូនោះក្លាយជាគំរូនិទណ្ឌភាពយ៉ាងធ្ងន់ធ្ងរ ដោយបង្កើតជាយុត្តិសាស្ត្រមួយយ៉ាងគ្រោះថ្នាក់ដល់សិទ្ធិជនរងគ្រោះក្នុងកម្រិតជាអន្តរជាតិ។ បទដ្ឋានដែលបានបង្កើតឡើងដោយ ស.ច.ស ក្នុងសំណុំរឿង០០៣

[៨៧] សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១, ឯកសារលេខ D26/1, នៅគេហទំព័រ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/D26_1_EN.PDF។

[៨៨] សូមមើលគេហទំព័រផ្លូវការរបស់ អ.វ.ត.ក នៅ៖ http://www.eccc.gov.kh/en/about-eccc/introduction, ចូលមើលនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១, គូសបញ្ជាក់បន្ថែម។

នេះ គឺជាការខ្វះខាតនូវការស៊ើបអង្កេត ដែលស្ថិតក្រោមឥទ្ធិពលនយោបាយ ពុំមានតម្លាភាព ធ្វើឲ្យប៉ះពាល់ដល់រងគ្រោះ និងបដិសេធការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

១០២. ស.ច.ស កំពុងរារាំងដំណើរការស្វែងរកយុត្តិធម៌ និងការយកឈ្នះលើនិទណ្ឌភាពរបស់ អ.វ.ត.ក ហើយដីកាដែលបដិសេធពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០៣ គឺជាឧទាហរណ៍មួយទៀតដែលវិសាលភាពនៃការជ្រៀតជ្រែកផ្នែកនយោបាយ បានលេចចេញជារូបរាងឡើងនៅតុលាការនេះ។

១០៣. សម្រាប់សំអាងហេតុតាមផ្លូវច្បាប់ក្នុងបណ្តឹងឧទ្ធរណ៍នេះ បើផ្អែកលើខ្លឹមសារដ៏ត្រឹមត្រូវរបស់ច្បាប់/វិធានផ្ទៃក្នុង និងការអនុវត្តយ៉ាងត្រឹមត្រូវនូវច្បាប់/វិធានផ្ទៃក្នុង ចំពោះអង្គហេតុនានាដែលមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវតែត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣។

១០៤. សរុបសេចក្តីមក ការមិនបានបំពេញកិច្ចស៊ើបអង្កេតឲ្យបានសព្វគ្រប់ ដោយឯករាជ្យ និងជៀសផុតពីការជ្រៀតជ្រែកផ្នែកនយោបាយ និងពីមូលហេតុដទៃទៀតដែលមិនច្បាស់លាស់របស់ ស.ច.ស ម្នាក់ និង/ឬ ទាំងពីរនាក់ ធ្វើឲ្យពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធចោលដោយមិនផ្តល់សំអាងហេតុសមស្របទេ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើថាដីកាបដិសេធលើការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពិតជាមិនត្រឹមត្រូវ ហើយបានរំលោភបំពានទៅលើវិធាន១៤(១) វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង មាត្រា១០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥(២) និង(៣) នៃកិច្ចព្រមព្រៀង និងគោលការណ៍អង្គការសហប្រជាជាតិប្រឆាំងនិទណ្ឌភាព។

## VII. សេចក្តីសន្និដ្ឋាន និងសំណើសុំ

១០៥. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះមេត្តា៖

i. ប្រកាសថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន និង

ii. ច្រានចោលសេចក្តីសម្រេចនៅក្នុងដីការបស់សហចៅក្រមស៊ើបអង្កេតដែលសម្រេចបដិសេធមិនទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ជាដើមបណ្តឹងរដ្ឋប្បវេណី និង

iii. ផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០៣ និង

iv. បង្គាប់ឱ្យ ស.ច.ស ផ្តល់សិទ្ធិដល់អ្នកតំណាងស្របច្បាប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការចូលមើលសំណុំរឿង និង

v. អនុញ្ញាតឱ្យមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មានពេលវេលាសមរម្យ ក្នុងការដាក់សារណាបន្ថែមទៀត ដើម្បីគាំទ្រដល់បណ្តឹងឧទ្ធរណ៍នេះ បន្ទាប់ពីបានអនុញ្ញាតឱ្យចូលមើលសំណុំរឿង០០៣ រួចហើយ (៣០ ថ្ងៃយ៉ាងតិច)។

សូមដាក់ជូនបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរពពី៖

| | |
|---|---|
| លោក **ហុង គីមសួន** | លោកស្រី Silke STUDZINSKY |
| សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី |

បានចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១។